ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅណែនាំ

## សម្រាប់

## ការពិនិត្យបញ្ជីឈ្មោះ

## និងការចុះឈ្មោះបោះឆ្នោត

## ឆ្នាំ២០២៦

# មាតិកា

គោលបំណង ........ ១
I. ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ........ ២
១. ការិយាល័យចុះឈ្មោះបោះឆ្នោត និងរយៈពេលនៃការចុះឈ្មោះបោះឆ្នោត ........ ២
ក. ការិយាល័យចុះឈ្មោះបោះឆ្នោត ........ ២
ខ. ការិយាល័យបោះឆ្នោត ........ ២
គ. រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ៣
ឃ. គំនូសតាងស្តីពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ៤
២. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ........ ៥
៣. ការប្រើប្រាស់បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ........ ៥
៤. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់) ........ ៥
ក. បរិវេណខាងក្នុង ........ ៥
ខ. បរិវេណខាងក្រៅ ........ ៥
៥. វិធានការការពារសន្តិសុខនៅការិយាល័យចុះឈ្មោះបោះឆ្នោត ........ ៦
៦. វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ ........ ៨
II. ការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ........ ៨
១. ការទទួលខុសត្រូវរបស់ កបឃ.ស ក្នុងដំណើរការចុះឈ្មោះបោះឆ្នោត ........ ៨
ក. ការអនុវត្តសិទ្ធិអំណាចដែល គ.ជ.ប បានធ្វើប្រតិភូកម្មឱ្យ ........ ៨
ខ. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ១១
២. តួនាទី និងភារកិច្ចរបស់ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ........ ១២
ក. តួនាទី និងភារកិច្ចរបស់ប្រធាន ក.ច.ប ........ ១៣
ខ. តួនាទី និងភារកិច្ចរបស់អនុប្រធាន ក.ច.ប ........ ១៥
គ. តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ ........ ១៦
ឃ. តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ក.ច.ប ........ ១៨
ង. ក្រុមចុះឈ្មោះបោះឆ្នោតពិសេស (ក.ច.ប.ព) ........ ១៩
III. ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត ........ ២០
១. លក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត ........ ២០

២.ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត ........ ២១

៣. គំរូប្លង់ការិយាល័យចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ........ ២២

IV. ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ២៤

១. សម្ភារ បរិក្ខារ និងកំព្យូទ័រសម្រាប់ការចុះឈ្មោះបោះឆ្នោត ........ ២៥

២.ជំហានទាំង៣ នៃការចុះឈ្មោះបោះឆ្នោត ........ ២៥

៣.ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ........ ២៨

ក. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ........ ២៩

ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ប៉ុន្តែអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត និងមិនបានយកមកជាមួយនូវសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ ........ ៣០

គ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ហើយអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះ និងគ្មានសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់នោះ ........ ៣១

៤. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ ........ ៣២

ក. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ នៅឃុំ សង្កាត់ផ្សេង ........ ៣២

ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេង ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ៣៤

៥. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពក្នុងរយ:ពេលយ៉ាងតិច ១០ឆ្នាំ ........ ៣៥

ក. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំប្តូរការិយាល័យបោះឆ្នោត ........ ៣៥

ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំកែតម្រូវទិន្នន័យ ឬ/និងផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត ........ ៣៦

គ. ករណីអ្នកបោះឆ្នោតស្នើសុំធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ ........ ៣៧

៦. ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ........ ៣៧

៧. ការអនុវត្តរបស់ ក.ច.ប លើរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត... ៣៧

៨. បែបបទ និងនីតិវិធីនៃការផ្តល់ ឯ.អ ........ ៣៨

៩. បែបបទ និងនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ........ ៣៩

V. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ........ ៤០

១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស ..................................................... ៤០
២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ..................................................... ៤៣
៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ..................................................... ៤៣
៤. តំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ..... ៤៤
VI. របាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងការវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ខប ..................................................... ៤៥
១. ការបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១).... ៤៥
២. ការវេចខ្ចប់កញ្ចប់ «ក» តាមការិយាល័យបោះឆ្នោតនីមួយៗ ..................................................... ៤៦
៣. ការបំពេញរបាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ..................................................... ៤៧
៤. ការបំពេញរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ..................................................... ៤៨
៥. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយ និងទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ........... ៤៨
ក. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ ..................................................... ៤៨
ខ. ការវេចខ្ចប់កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ..... ៤៩
៦. ការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោង «ខ» បញ្ជូនទៅ លធ.ខប ..................................................... ៥០
ក. ការវេចខ្ចប់ស្បោង «ខ» ទី១ ..................................................... ៥០
ខ. ការវេចខ្ចប់ស្បោង «ខ» ទី២ និងស្បោង «ខ» បន្តបន្ទាប់ ..................................................... ៥២
៧. ការបញ្ជូនស្បោង «ខ» ទៅ លធ.ខប ..................................................... ៥៣
៨. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប និងការវេចខ្ចប់ស្បោង «ខ» ដាក់ក្នុងស្បោង «គ» បញ្ជូនទៅនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ..................................................... ៥៤
ក. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប ..................................................... ៥៤
ខ. ការវេចខ្ចប់ស្បោង «គ» បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត .............. ៥៧
៩. ការវេចខ្ចប់សម្ភារ ឯកសារផ្សេងៗទៀត ដែលបានផ្គត់ផ្គង់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតបញ្ជូនទៅ គ.ជ.ប .......... ៥៩
VII. ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតជាសាធារណៈ សម្រាប់គោលដៅនៃការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ ..................................................... ៥៩

១. ទីកន្លែងផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង ........ ៥៩
២. កាលបរិច្ឆេទនៃការផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង ........ ៦០
VIII. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង .... ៦០
១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់នៅ កបឃ.ស ........ ៦១
ក. ការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ........ ៦១
ខ. ការទទួលពាក្យបណ្តឹង ........ ៦១
គ. ការប្រជុំសម្រេចជាសាធារណៈ ........ ៦២
២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ........ ៦៣
៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ........ ៦៣
៤. ការបំពេញរបាយការណ៍ស្តីពីសេចក្តីសម្រេចកែតម្រូវលើបញ្ជីបោះឆ្នោតដំបូង (ទ.១០២០) ........ ៦៤
៥. តំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ........ ៦៥
ក. ករណីពាក្យបណ្តឹងតវ៉ា ........ ៦៥
ខ. ករណីពាក្យបណ្តឹងជំទាស់ ........ ៦៦
៦. ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ ........ ៦៧
៧. ការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបាត់បង់លក្ខខណ្ឌមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងការស្រង់ឈ្មោះប្រជាពលរដ្ឋខ្មែរដែលត្រូវបំពេញលក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅក្រោយពេល គ.ជ.ប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ........ ៦៧

# អក្សរកាត់

| | | |
|---|---|---|
| ១. | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. | លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត | លធ.ខប |
| ៣. | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ៤. | ក្រុមចុះឈ្មោះបោះឆ្នោត | ក.ច.ប |
| ៥. | ក្រុមចុះឈ្មោះបោះឆ្នោតពិសេស | ក.ច.ប.ព |
| ៦. | ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| ៧. | ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ៨. | ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្ដីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ឃ.ស |
| ៩. | ច្បាប់ស្ដីពីវិសោធនកម្មច្បាប់បោះឆ្នោត | ច.វ.ច.ប |
| ១០. | បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ | ប.ន.ព.ច |
| ១១. | អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១២. | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត | ឯ.អ |
| ១៣. | នាយកដ្ឋាន | ន. |
| ១៤. | នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត | ន.គ.ទ.ប |
| ១៥. | ទម្រង់បែបបទលេខ | ទ. |

# គោលបំណង

សៀវភៅណែនាំនេះមានគោលបំណងពន្យល់អំពីនីតិវិធី បច្ចេកទេស បទប្បញ្ញត្តិ និងគោលការណ៍សំខាន់ៗនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមកម្មវិធីកុំព្យូទ័រ ដើម្បីឱ្យមន្ត្រីចុះឈ្មោះបោះឆ្នោត ពិសេសក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) និងក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ទាំងអស់សិក្សាស្វែងយល់ និងអនុវត្តការងារតាមតួនាទី ភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងប្រកបដោយលទ្ធផលល្អ។

សៀវភៅណែនាំនេះក៏ជាជំនួយដ៏សំខាន់សម្រាប់គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល អ្នកសង្កេតការណ៍បោះឆ្នោត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីសិក្សាស្វែងយល់ និងរួមសហការអនុវត្តតាមតួនាទីរបស់ខ្លួន ដើម្បីឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦នេះ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព។

អនុលោមតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ សេចក្តីសម្រេចស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ និងប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ ឬតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ចាប់ផ្តើមពី**ថ្ងៃទី៧ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦។**

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦នេះ គឺជាការចុះឈ្មោះចំពោះប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំឡើង អ្នកដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក និងអ្នកទើបបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី ការកែតម្រូវទិន្នន័យជីវប្រវត្តិ (ប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត) និងការធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (ថតរូប និងផ្តិតមេដៃ) ចំពោះអ្នកចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ ដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតតាមសំណើសុំរបស់សាមីខ្លួន និងការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតចំពោះអ្នកដែលបានទទួលមរណភាព អ្នកដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត និងអ្នកដែលបាន ផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ ផ្សេងដោយផ្អែកតាមឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់។ ការងារនេះត្រូវធ្វើតាមកម្មវិធីកុំព្យូទ័រ និងការបញ្ជូនទិន្នន័យតាមអ៊ីនធឺណិតមក គ.ជ.ប ជាប្រចាំ ដើម្បីរៀបចំបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតសម្រាប់បិទផ្សាយបម្រើឱ្យគោលដៅនៃការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ បន្ទាប់មកផ្តល់សុពលភាពជាបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៦ សម្រាប់ប្រើប្រាស់តាមការកំណត់នៃច្បាប់។

ប្រជាពលរដ្ឋខ្មែរដែលមានអាយុ១៨ឆ្នាំឡើង គិតដល់**ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)** អ្នកដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក អ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី អ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ដែលមានបំណងកែតម្រូវទិន្នន័យ ជីវប្រវត្តិ ឬធ្វើបច្ចុប្បន្នទិន្នន័យជីវមាត្រ ត្រូវទៅជួបក្រុមចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោត ដែលមានទីតាំងនៅសាលាឃុំ សង្កាត់ ឬតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ ដើម្បីសុំចុះឈ្មោះបោះឆ្នោត និងសុំធ្វើការកែតម្រូវទិន្នន័យ។

# ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

## I. ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

### ១. ការិយាល័យចុះឈ្មោះបោះឆ្នោត និងរយៈពេលនៃការចុះឈ្មោះបោះឆ្នោត

#### ក. ការិយាល័យចុះឈ្មោះបោះឆ្នោត

ជាគោលការណ៍ ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវមានទីតាំងនៅសាលាឃុំ សង្កាត់ ហើយការិយាល័យចុះឈ្មោះបោះឆ្នោតនេះនឹងត្រូវប្តូរទីតាំងទៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់។ ការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវរៀបចំឱ្យមានលក្ខណៈងាយស្រួលដល់ជនមានពិការភាពក្នុងការសុំចុះឈ្មោះបោះឆ្នោត។

ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅសាលាឃុំ សង្កាត់ គឺជាការិយាល័យចុះឈ្មោះបោះឆ្នោតចម្បង ដែលត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ នៅថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ ដោយប្រើរយៈពេលប្រមាណមួយភាគពីរនៃរយៈពេលចុះឈ្មោះបោះឆ្នោតសរុប។

ការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅតាមភូមិមួយចំនួនក្រៅពីសាលាឃុំ សង្កាត់ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដោយប្រើរយៈពេលសរុបមិនឱ្យលើសពីមួយភាគពីរនៃរយៈពេលរួម ដែលបានកំណត់ឡើយ។

កបឃ.ស និង ក.ច.ប អាចធ្វើការកែសម្រួលរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតខាងលើទៅតាមកាលៈទេសៈ និងស្ថានភាពភូមិសាស្ត្រជាក់ស្តែងដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់មានលទ្ធភាពមកពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតគ្រប់ៗគ្នា។

ការិយាល័យចុះឈ្មោះបោះឆ្នោតនីមួយៗ ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត សម្រាប់ប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតមកពីគ្រប់ភូមិក្នុងព្រំប្រទល់ឃុំ សង្កាត់។

#### ខ. ការិយាល័យបោះឆ្នោត

- ការិយាល័យបោះឆ្នោតមួយ ឬច្រើននឹងត្រូវបានបង្កើតឡើងក្នុងភូមិចំណុះឱ្យឃុំ សង្កាត់នីមួយៗទូទាំងប្រទេស ហើយការិយាល័យបោះឆ្នោតនីមួយៗត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់ក្នុងព្រំប្រទល់ឃុំ សង្កាត់របស់ខ្លួន
- ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតយ៉ាងច្រើន ៧៥០នាក់។ ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយមានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះ ទៅក្នុងការិយាល័យបោះឆ្នោតណាមួយក្នុងភូមិជាមួយ ឬការិយាល័យបោះឆ្នោតណាដែលនៅជិតបំផុតក្នុងឃុំ សង្កាត់ជាមួយ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងភូមិជាមួយ តាមការចាំបាច់។

### គ. រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ មានរយៈពេល **៥៥ ថ្ងៃ**។

- ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើមធ្វើនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេសក្នុងថ្ងៃតែមួយ **គឺថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៦** និងត្រូវបញ្ចប់នៅ **ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦**
- នៅថ្ងៃចាប់ផ្តើមដំបូង ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបើកដំណើរការនៅសាលាឃុំ សង្កាត់
- ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការជារៀងរាល់ថ្ងៃ គិតទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ចាប់ពីម៉ោង ៧:០០ ព្រឹក រហូតដល់ម៉ោង ១១:៣០នាទីថ្ងៃត្រង់ និងពីម៉ោង២:០០ រសៀល រហូតដល់ម៉ោង ៥:៣០នាទីល្ងាច។ ក្នុងករណីមានអ្នកសុំចុះឈ្មោះបោះឆ្នោតបន្ត គបឃ.ស និង គ.ច.ប អាចបន្ថែមម៉ោងពេលនៃការចុះឈ្មោះបោះឆ្នោតតាមការជាក់ស្តែង
- ការិយាល័យចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ត្រូវបើកបម្រើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតជាប់រហូត តាមរយៈពេលបានកំណត់ខាងលើ លើកលែងតែករណីប្រធានសក្តិ។ ក្នុងករណីនេះ ដោយមានការឯកភាពពី គបឃ.ស គ.ច.ប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ដើម្បីសុំការសម្រេចពី គ.ជ.ប
- នៅគ្រប់ពេលក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត គ.ច.ប ត្រូវទទួលចុះឈ្មោះជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ឬកែតម្រូវ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យអ្នកស្នើសុំដែលមកពីគ្រប់ភូមិក្នុងឃុំ សង្កាត់ ទោះបីកំពុងធ្វើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅទីតាំងភូមិណាមួយក៏ដោយ
- ក្នុងករណីដែលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតមិនទាន់ផុតរយៈពេលកំណត់ ប៉ុន្តែការិយាល័យបោះឆ្នោតនីមួយៗសុទ្ធតែបានចុះឈ្មោះអ្នកបោះឆ្នោតគ្រប់ចំនួន ៧៥០នាក់ហើយ ប្រសិនបើនៅតែមានអ្នកមកសុំចុះឈ្មោះបោះឆ្នោតទៀត គ.ច.ប ដោយមានការឯកភាពពី គបឃ.ស ត្រូវលើកសំណើជាបន្ទាន់តាមរយៈ លធ.ខប មក គ.ជ.ប ដើម្បីសុំបង្កើតការិយាល័យបោះឆ្នោតថ្មី
- គបឃ.ស ត្រូវកំណត់ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត សម្រាប់ការិយាល័យចុះឈ្មោះបោះឆ្នោត នៅតាមភូមិមួយចំនួនក្រៅពីការិយាល័យនៅសាលាឃុំ សង្កាត់ តាមសំណើរបស់ គ.ច.ប។ ក្នុងករណីនេះ គ.ច.ប ត្រូវសហការឱ្យបានជិតស្និទ្ធជាមួយមេភូមិពាក់ព័ន្ធ ដើម្បីចាត់ចែងអនុវត្តការងារតាមប្រតិទិនដែលបានកំណត់ ហើយ គបឃ.ស និង គ.ច.ប ត្រូវជូនដំណឹងទៅគ្រប់ភាគីពាក់ព័ន្ធអំពីការកំណត់ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនេះ

- គ.ច.ប អាចកែសម្រួលកាលវិភាគនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមភូមិតាមការចាំបាច់ និងតាមសភាពជាក់ស្តែង ប៉ុន្តែត្រូវធានាថា រាល់ការកែសម្រួល ត្រូវតែបានជូនដំណឹងជាសាធារណៈដល់មេភូមិ ប្រជាពលរដ្ឋ ភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍បោះឆ្នោត
- នៅតំបន់ដែលប្រជាពលរដ្ឋខ្មែរពុំអាចមកបង្ហាញខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីចុះឈ្មោះបោះឆ្នោតនៅក្នុងម៉ោងធ្វើការធម្មតាបាន ដោយសារពួកគាត់ជាប់រវល់ធ្វើស្រែចម្ការ ឬធ្វើការងារនៅទីឆ្ងាយ គ.ច.ប ត្រូវសម្របសម្រួលម៉ោងធ្វើការប្រចាំថ្ងៃនៃការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋខ្មែរទាំងនោះអាចមកចុះឈ្មោះបោះឆ្នោតបាន។ គបឃ.ស និង គ.ច.ប ត្រូវជូនដំណឹងដល់គ្រប់ភាគីពាក់ព័ន្ធអំពីការកែសម្រួលម៉ោងធ្វើការប្រចាំថ្ងៃរបស់ គ.ច.ប។

### ឃ. គំនូសតាងស្តីពីរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមឃុំ សង្កាត់មានរយៈពេល ៥៥ ថ្ងៃ តាមគំនូសតាងដូចខាងក្រោម៖

| រយៈពេល ១៥ ថ្ងៃ នៅសាលាឃុំ សង្កាត់ | រយៈពេល ២៥ ថ្ងៃ នៅតាមទូទីមួយចំនួន | រយៈពេល ១៥ ថ្ងៃ នៅសាលាឃុំ សង្កាត់ |
|---|---|---|
| ថ្ងៃទី៧ ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៦ | ថ្ងៃទី២២ ខែតុលា ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៦ | ថ្ងៃទី១៦ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦ |

**សម្គាល់៖**

- ក្នុងករណីចាំបាច់ គ.ច.ប អាចកែសម្រួលរយៈពេលចុះឈ្មោះបោះឆ្នោតតាមភូមិ ដោយត្រូវជូនដំណឹងដល់មេភូមិ ប្រជាពលរដ្ឋ ភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍បោះឆ្នោត
- ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ គបឃ.ស ត្រូវបិទការិយាល័យចុះឈ្មោះបោះឆ្នោតចំនួន ៤ (បួន) លើក ដើម្បីបើកកិច្ចប្រជុំជាមួយ គ.ច.ប ត្រួតពិនិត្យការអនុវត្តដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ កិច្ចប្រជុំត្រួតពិនិត្យនេះត្រូវប្រព្រឹត្តទៅ **នៅថ្ងៃទី១២ ថ្ងៃទី២៩ ខែតុលា ថ្ងៃទី៩ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៦**។

## ២. ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

- កបឃ.ស ត្រូវបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតនៅសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនមួយចំនួនក្នុងឃុំ សង្កាត់ យ៉ាងតិច ១០ថ្ងៃ មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត **(បិទផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦)**
- កបឃ.ស និងប្រធាន ក.ច.ប ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីរយៈពេលកាលបរិច្ឆេទ និងប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន (នៅសាលាឃុំ សង្កាត់ និងនៅតាមភូមិមួយចំនួន ដែលបានកំណត់) ក្នុងរយៈពេលយ៉ាងតិច ៣ថ្ងៃ មុនថ្ងៃចាប់ផ្តើមធ្វើការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

## ៣.ការប្រើប្រាស់បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥

បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ដែល គ.ជ.ប ផ្តល់សុពលភាពចុងក្រោយ ត្រូវបិទផ្សាយនៅសាលាឃុំ សង្កាត់យ៉ាងតិច ១០ថ្ងៃ មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ (បិទផ្សាយនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦)។ បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ចំនួន ៣ច្បាប់ ត្រូវប្រើប្រាស់ដូចខាងក្រោម ៖

*បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ចំនួន ៣ច្បាប់*

- *១ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់ **នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦***
- *១ច្បាប់ បិទផ្សាយជាសាធារណៈនៅតាមទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ **នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦***
- *១ច្បាប់ សម្រាប់ ក.ច.ប ប្រើប្រាស់។*

☛ **សម្គាល់** ៖ បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ក៏មានបង្ហោះលើអាសយដ្ឋានវេបរបស់ គ.ជ.ប voterlist.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH។

## ៤. បរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត (ក្រៅពីសាលាឃុំ សង្កាត់)

### ក. បរិវេណខាងក្នុង

បរិវេណខាងក្នុង ជាតំបន់ព័ទ្ធជុំវិញការិយាល័យចុះឈ្មោះបោះឆ្នោតតាំងនៅដែលខណ្ឌដោយវណ្ឌមណ្ឌលដែលមានកាំប្រវែងយ៉ាងតិច ១៥ម៉ែត្រ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចូលមួយ និងច្រកចេញមួយ។

### ខ. បរិវេណខាងក្រៅ

បរិវេណខាងក្រៅ ជាតំបន់ព័ទ្ធជុំវិញការិយាល័យចុះឈ្មោះបោះឆ្នោតតាំងនៅ ហើយដែលខណ្ឌដោយវណ្ឌមណ្ឌលមួយមានកាំប្រវែង ១០០ម៉ែត្រ ឬតូចជាងអាស្រ័យដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជាបរិវេណរបងវត្តអារាម សាលារៀន សាលមហោស្រព ទីធ្លាសាធារណៈ ជាដើម។

នៅតំបន់ទីប្រជុំជន បរិវេណខាងក្រៅនៃការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដោយ កបឃ.ស ផ្អែកតាមស្ថានភាពជាក់ស្តែងនៃតំបន់នោះ។

សាលារៀន ទីវត្តអារាម និងរាល់សំណង់ អគារ សាល និងទីធ្លាសាធារណៈ ត្រូវបានផ្តល់ដោយឥតគិតថ្លៃទៅ គ.ជ.ប សម្រាប់គោលបំណងនៃការរៀបចំជាការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីចុះឈ្មោះបោះឆ្នោត។

### ៩. វិធានការការពារសន្តិសុខនៅការិយាល័យចុះឈ្មោះបោះឆ្នោត

ដើម្បីការពារអ្នកនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុង និងបរិវេណខាងក្រៅនៃការិយាល័យទាំងនោះ ឱ្យចៀសផុតពីការរំខាន ការអុកឡុក ការបំភិតបំភ័យ ការគំរាមកំហែង ឬអំពើហិង្សា និងរក្សាការពារសម្ភារ បរិក្ខារ ឯកសារទាំងអស់ក្នុងការិយាល័យទាំងនោះ ព្រមទាំងធានានូវការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប ក្នុងនោះ ប្រធាន ក.ច.ប ត្រូវចាត់វិធានការចាំបាច់នានា ដូចខាងក្រោម៖

- ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ ឬសារធាតុ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងការស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត លើកលែងតែក្នុងករណីមានការបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដែលក្នុងករណីនេះ គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប អាចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចបាន
- ហាមជនគ្រប់រូបដែលព្យាយាមដោយទុច្ចរិតធ្វើសកម្មភាពគ្រប់រូបភាព និងមធ្យោបាយនានា ដើម្បីប្រមូល ឬទទួលបាននូវទិន្នន័យព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ឬ/និងប្រព័ន្ធបញ្ជីបោះឆ្នោត ដោយគ្មានការអនុញ្ញាតពី គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ ក.ច.ប។ ក្នុងករណីនេះ កបឃ.ស និង ក.ច.ប ត្រូវចាត់វិធានការជាបន្ទាន់ភ្លាម ដើម្បីបញ្ឈប់សកម្មភាពទាំងនេះ
- ក្នុងករណីមានសំណូមពរពី គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតណាមួយនោះ ភ្នាក់ងារសន្តិសុខដែលមានបំពាក់អាវុធសមស្រប អាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធបាន
- ហាមជនគ្រប់រូបចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត មុនពេលការិយាល័យចាប់ផ្តើមធ្វើការ ឬក្រោយពេលបិទទ្វារ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប។

**ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងបរិវេណខាងក្នុង ក្នុងពេលដំណើរការចុះឈ្មោះបោះឆ្នោតនូវជនទាំងឡាយដូចខាងក្រោម៖**

- ក.ច.ប ដែលបានទទួលការតែងតាំងពី គ.ជ.ប
- ថ្នាក់ដឹកនាំ និងមន្ត្រី គ.ជ.ប និង លធ.ឌប ដែលមានភារកិច្ច
- សមាជិក កបឃ.ស ដែលប្រចាំការពិនិត្យមើលដំណើរប្រព្រឹត្តទៅនៃ ក.ច.ប ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ភ្នាក់ងារគណបក្សនយោបាយនីមួយៗ ចំនួន ២ (ពីរ) រូប (ពេញសិទ្ធិ ១រូប និងបម្រុង ១រូប) ដែលទទួលបានការអនុញ្ញាតពី កបឃ.ស។ ភ្នាក់ងារពេញសិទ្ធិ ១ (មួយ)រូប ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។ ភ្នាក់ងារបម្រុង ១ (មួយ) រូប ត្រូវបានអនុញ្ញាតឱ្យចាំនៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិក្នុងករណីផ្លាស់ប្តូរ ឬអវត្តមាន
- អ្នកសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មាន ដែលទទួលស្គាល់ដោយ គ.ជ.ប
- ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត ហើយមានបំណងសុំចុះឈ្មោះបោះឆ្នោត ឬអ្នកស្នើសុំកែតម្រូវ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោត
- នីតិជនអមដំណើរអ្នកសុំចុះឈ្មោះបោះឆ្នោតជាជនមានពិការភាព ដែលមិនអាចសុំចុះឈ្មោះបោះឆ្នោតបានដោយខ្លួនឯង
- ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែល គ.ជ.ប ឬ លធ.ឌប ឬ កបឃ.ស ឬ/និង ក.ច.ប សំណូមពរក្នុងករណីចាំបាច់។

**សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវបានហាមឃាត់នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ៖**

- ការស្លៀកពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ ការស្លៀកពាក់ ឬការបិទផ្សាយស្លាកសញ្ញា ឬការនិយាយដែលមានការពាក់ព័ន្ធជាមួយគណបក្សនយោបាយណាមួយ
- ការបង្ហាញការគាំទ្រ ឬការប្រឆាំងចំពោះគណបក្សនយោបាយណាមួយ
- ការរារាំង ឬការញុះញង់ប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតមិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬការរារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត
- ការបង្កការអុកឡុក ឬការរារាំងសកម្មភាពជាប្រក្រតីក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតនៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

- ការព្យាយាមដោយទុច្ចរិតតាមគ្រប់មធ្យោបាយ ឬ/និងរូបភាព ដើម្បីប្រមូល ឬទទួលបានព័ត៌មាន ឬ/និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត និងប្រព័ន្ធបញ្ជីបោះឆ្នោតដែលធ្វើឱ្យបាត់ការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត
- ការប្រើសម្ភារ បរិក្ខារដើម្បីថតផ្តិតយករូបភាព សំឡេង ឬសកម្មភាពផ្ទាល់ទាំងឡាយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ដោយគ្មានការអនុញ្ញាតពី ក.ច.ប ឬ កបឃ.ស ឬ លធ.ខប ឬ គ.ជ.ប។

ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងណែនាំរបស់ គ.ជ.ប ឬ លធ.ខប ឬ កបឃ.ស ឬ/និង ក.ច.ប ស្របតាមលក្ខខណ្ឌនៃ ច.ប.ត.រ និង ប.ន.ព.ច។

**៦. វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ**

គ.ជ.ប ត្រូវចាត់វិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការចាំបាច់ផ្សេងៗទៀត ដើម្បីបង្ការការពារ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

ជនគ្រប់រូបដែលនៅបរិវេណខាងក្នុង បរិវេណខាងក្រៅ និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវគោរពតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំផ្សេងៗស្តីពីវិធានការការពារ និងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗ ក្នុងករណីតម្រូវឱ្យអនុវត្ត។

## II. ការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស)

កបឃ.ស ត្រូវបំពេញតួនាទីជាតំណាង គ.ជ.ប ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត សម្រាប់ឃុំ សង្កាត់រៀងៗខ្លួនដោយអនុវត្តតាមសេចក្តីសម្រេចរបស់ គ.ជ.ប លេខ ០៦៣/១៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

**១. ការទទួលខុសត្រូវរបស់ កបឃ.ស ក្នុងដំណើរការចុះឈ្មោះបោះឆ្នោត**

**ក. ការអនុវត្តសិទ្ធិអំណាចដែល គ.ជ.ប បានធ្វើប្រតិភូកម្មឱ្យ**

ក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត កបឃ.ស ត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

- ជាជំនួយដល់ គ.ជ.ប តាមរយៈ លធ.ខប ក្នុងការកំណត់ចំនួន និងទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត

- ជាជំនួយដល់ គ.ជ.ប តាមរយៈ លធ.ខប ក្នុងការផ្តល់ស្ថិតិប្រជាពលរដ្ឋខ្មែរ ដែលមានអាយុចាប់ពី១៨ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
- ចូលរួមជាសមាសភាពអនុគណៈកម្មការជ្រើសរើស ក.ច.ប នៃឃុំ សង្កាត់
- បិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២៥
- ត្រូវដឹកនាំ ក.ច.ប ឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ត.រ) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ (ច.ប.ឃ.ស) ច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត (ច.វ.ច.ប) និងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ (ប.ន.ព.ច)
- ចាត់សមាជិក កបឃ.ស របស់ខ្លួន ១រូប ទៅ ២រូប ចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សា ៥រូប និង ២រូប ទៅ ៣រូប ចំពោះឃុំ សង្កាត់ណាដែលមានសមាជិកក្រុមប្រឹក្សាចាប់ពី ៧រូបឡើងទៅ ឱ្យប្រចាំការពិនិត្យមើលដំណើរប្រព្រឹត្តទៅនៃ ក.ច.ប ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។ ធានាឱ្យមានសមាសភាពពីគ្រប់គណបក្សនយោបាយដែលមានអាសនៈក្នុង កបឃ.ស (ប្រសិនបើមាន) ចូលរួមប្រចាំការពិនិត្យមើលដំណើរប្រព្រឹត្តទៅនៃ ក.ច.ប។ សមាជិកដែលប្រចាំការនេះមិនទទួលប្រាក់កម្រៃបន្ថែមឡើយ
- ទទួលពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយចូលរួមសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ព្រមទាំងពិនិត្យសម្រេច និងចេញបណ្ណសម្គាល់ខ្លួនជូនភ្នាក់ងារគណបក្សនយោបាយតាមការណែនាំរបស់ គ.ជ.ប
- ទទួលបន្ទុកអប់រំ ផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ឱ្យទៅចុះឈ្មោះបោះឆ្នោត ឬពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួននៅលើបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២៥ ដែលបានបិទផ្សាយនៅតាមសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ ដើម្បីបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ទទួលបន្ទុកអប់រំ ផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋខ្មែរកំពុងរស់នៅក្នុងឃុំ សង្កាត់ ឱ្យទៅពិនិត្យ ផ្ទៀងផ្ទាត់ឈ្មោះ ឬ/និងទិន្នន័យពាក់ព័ន្ធរបស់ខ្លួននៅលើបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ដែលបានបិទផ្សាយនៅសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ ដើម្បីបម្រើគោលដៅនៃការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់

- ចាត់ចែង និងដឹកនាំការងារចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥
- ធានាចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) និងលិខិតបញ្ជាក់ទីលំនៅ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោតដែលបានស្នើសុំស្របតាមច្បាប់ ដោយពុំមានតម្រូវឱ្យបង់កម្រៃសេវាឡើយ។ ដើម្បីបម្រើគោលដៅនេះ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ដែលត្រូវបានប្រគល់សិទ្ធិអំណាចក្នុងការចេញលិខិតបញ្ជាក់ទាំងនេះ ត្រូវមានវត្តមាននៅសាលាឃុំ សង្កាត់ ឬត្រូវចុះជាប់ជាមួយ ក.ច.ប ស្របពេលនឹងការចុះឈ្មោះបោះឆ្នោតនៅតាមទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ឬចល័តតាមភូមិ
- ធានាផ្តល់ជំនួយសមស្រប ចំពោះជនដែលមានពិការភាពដែលមិនអាចសុំចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងបាន និងដែលបានស្នើសុំជំនួយ
- ទទួល និងដោះស្រាយរាល់ពាក្យបណ្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដោយការប្រជុំសម្រេចជាសាធារណៈ
- ទទួល និងដោះស្រាយរាល់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង ដោយការប្រជុំសម្រេចជាសាធារណៈ
- ទទួល និងដោះស្រាយពាក្យបណ្តឹងដែលអាចនាំឱ្យមានការដាក់ពិន័យតាមរយៈការប្រជុំផ្សះផ្សា ដោយផ្អែកលើសៀវភៅណែនាំស្តីពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦
- ផ្ញើជូន គ.ជ.ប នូវរាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ក្នុងការដោះស្រាយលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ឱ្យបានទាន់ពេលវេលា និងផ្តល់ពាក្យបណ្តឹង (ទ.១២០២) សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់តាមសំណើសុំរបស់អ្នកប្តឹង ឬតំណាង
- ផ្តល់ជំនួយដល់ ក.ច.ប ក្នុងការពិនិត្យផ្ទៀងផ្ទាត់ ការបូកសរុប ការរៀបចំវេចខ្ចប់ និងការបញ្ជូនលទ្ធផល និងសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតជូន គ.ជ.ប តាមរយៈ លធ.ឃប
- ចាត់ចែងឱ្យមានកម្លាំងរក្សាសណ្តាប់ធ្នាប់តាមលទ្ធភាព និងការចាំបាច់សម្រាប់សម្រួលដល់ការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់។ ការចាត់ចែងប្រើប្រាស់កម្លាំងរក្សាសណ្តាប់ធ្នាប់នេះស្ថិតក្នុងសមត្ថកិច្ច និងបន្ទុកដោះស្រាយរបស់ គបឃ.ស

- ចាត់វិធានការសមស្របដើម្បីធានាថា រាល់កិច្ចប្រតិបត្តិការទាក់ទងដល់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតបានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង និងចាត់ចែងដោះស្រាយឱ្យមានអន្តរាគមន៍ពីកម្លាំងមានសមត្ថកិច្ច (នគរបាលជាតិ កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ) តាមសំណើរបស់ ក.ច.ប ក្នុងករណីដែលមានជនណាបង្កការអុកឡុក ការរំខាន ការគំរាមកំហែង ឬប្រព្រឹត្តអំពើល្មើសច្បាប់ សំដៅបង្អាក់ដំណាក់កាលណាមួយនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ចាត់ចែងអនុវត្ត ដើម្បីធានាឱ្យបាននូវវិធានការនានាពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងរក្សាបាននូវការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត
- នៅពេលបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត កបឃ.ស ត្រូវសហការជាមួយ លធ.ខប ដើម្បីធ្វើការវាយតម្លៃសមាសភាព ក.ច.ប។ ក្នុងការវាយតម្លៃនេះ កបឃ.ស ត្រូវទទួលខុសត្រូវធ្វើកំណត់ហេតុវាយតម្លៃ សមាសភាពក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០២៤) ដែលជាមន្ត្រីចុះឈ្មោះបោះឆ្នោតម្នាក់ៗ ដោយមានការយល់ស្របពី កបឃ.ស ប្រចាំការពិនិត្យមើលទាំងអស់ដោយផ្អែកលើការទទួលខុសត្រូវ និងភារកិច្ចរៀងខ្លួន (មានចែងនៅក្នុង ទ.១០២៤) រួចផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប។

## ខ. ការទទួលខុសត្រូវលើការងារសន្តិសុខសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

កបឃ.ស ត្រូវចាត់ចែងតាមលទ្ធភាព និងការចាំបាច់ឱ្យមានកម្លាំងរក្សាសណ្តាប់ធ្នាប់ដែលមានភារកិច្ចដូចខាងក្រោម៖

- សម្រួលសណ្តាប់ធ្នាប់សម្រាប់ប្រជាពលរដ្ឋ ដែលចូលមកកាន់ការិយាល័យចុះឈ្មោះបោះឆ្នោតដើម្បីសុំចុះឈ្មោះបោះឆ្នោត ឬសុំកែតម្រូវ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យ
- សម្រួលអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តង ៣នាក់
- ផ្តល់អាទិភាពចំពោះព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាពចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- អនុញ្ញាតឱ្យអ្នកជំនួយជានីតិជនម្នាក់ ជូនដំណើរជនមានពិការភាពដែលមិនអាចចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងបាន ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- រាយការណ៍ជាបន្ទាន់ជូន កបឃ.ស ក្នុងករណីមានការអុកឡុក ឬការរំខានពីជនណាម្នាក់ ឬច្រើននាក់ ដើម្បីមានវិធានការស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬ/និងអាជ្ញាធរមានសមត្ថកិច្ច។

២. តួនាទី និងភារកិច្ចរបស់ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប)

អនុលោមតាម ច.ប.ត.រ ប.ន.ព.ច និងសេចក្តីសម្រេចផ្សេងទៀត ដែលកំណត់ដោយ គ.ជ.ប ក.ច.ប ត្រូវទទួលខុសត្រូវអនុវត្តរាល់កិច្ចប្រតិបត្តិការ បម្រើឱ្យគោលបំណងនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្នុងការអនុវត្តភារកិច្ចនេះ ក.ច.ប ត្រូវ៖

- គោរព ច.ប.ត.រ ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ព.ច
- ប្រកាន់ជំហរឯករាជ្យ អព្យាក្រឹត និងមិនលម្អៀងក្នុងពេលបំពេញការងារ
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- យល់ដឹងយ៉ាងច្បាស់លាស់ និងចេះម្ចាស់ការបានលើរាល់នីតិវិធីពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ចាត់វិធានការចាំបាច់នានា ដើម្បីធានាឱ្យជនគ្រប់រូបបានចូលរួមប្រកបដោយសុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបំភិតបំភ័យក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលខ្លួនទទួលខុសត្រូវ សំដៅធ្វើឱ្យដំណើរការនេះប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព
- ចេះបំពេញទម្រង់បែបបទពាក់ព័ន្ធផ្សេងៗដែលបានកំណត់ ចេះធ្វើកុំព្យូទ័រកម្មទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោត និងចេះធ្វើរបាយការណ៍បានច្បាស់លាស់
- អនុវត្តតាមសេចក្តីសម្រេចរបស់ កបឃ.ស ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញក្នុងការចុះឈ្មោះបោះឆ្នោតជូនអ្នកសុំចុះឈ្មោះបោះឆ្នោត
- សហការជាមួយ លធ.ឧប ដើម្បីអនុវត្តនីតិវិធីលុបឈ្មោះអ្នកដែលទទួលមរណភាព អ្នកដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត អ្នកដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង និងសហការជាមួយ លធ.ឧប និង កបឃ.ស ដើម្បីជូនដំណឹងដល់អ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក ឬអ្នកទើបគ្រប់អាយុចុះឈ្មោះបោះឆ្នោត និងអ្នកដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មីឱ្យមកបំពេញលក្ខខណ្ឌចុះឈ្មោះ បោះឆ្នោត
- ត្រួតពិនិត្យផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពទិន្នន័យក្នុងបញ្ជីបោះឆ្នោតតាមអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (អ.ខ) ប្រភេទថ្មី តាមសំណើសុំរបស់សាមីខ្លួន
- រក្សាការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ដែលបានទទួលក្នុងដំណើរការនៃការចុះឈ្មោះបោះឆ្នោត

- ចាត់ចែងអនុវត្ត ដើម្បីធានាឱ្យបាននូវវិធានការនានាពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- ចាត់វិធានការបង្ការ និងទប់ស្កាត់នូវរាល់សកម្មភាពទាំងឡាយដែលបង្កការរំខាន ឬ/និងការរំលោភបំពានលើការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត លើកលែងតែមានការអនុញ្ញាតដូចមានចែងក្នុង ប.ន.ព.ច។ ការរំខាន ឬ/និងការរំលោភបំពានមានជាអាទិ៍ដូចខាងក្រោម៖
    - ការកត់ត្រា ឬការថតយកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតពីកុំព្យូទ័រ
    - ការកត់ត្រា ឬការថតឯកសាររបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
    - ការព្យាយាមតាមគ្រប់មធ្យោបាយផ្សេងទៀត ដើម្បីកត់ត្រា ឬថតឯកសារ ឬ/និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។

**ក. តួនាទី និងភារកិច្ចរបស់ប្រធាន ក.ច.ប**

ប្រធាន ក.ច.ប មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ធ្វើគំរូប្លង់ និងធានាថា ការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានសម្អាត និងថែរក្សាសុវត្ថិភាពបានល្អ
- រៀបចំការិយាល័យចុះឈ្មោះបោះឆ្នោត ដោយផ្អែកតាមពន្លឺដែលអាចឱ្យការីកុំព្យូទ័រនៃ ក.ច.ប អាចថតយករូបភាពអ្នកសុំចុះឈ្មោះបោះឆ្នោតបានច្បាស់ល្អ
- ត្រួតពិនិត្យ គ្រប់គ្រងបរិមាណ និងគុណភាពសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត
- ត្រួតពិនិត្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានការបញ្ជាក់ទទួលស្គាល់រួចហើយ ដើម្បីឱ្យពួកគេអនុវត្តភារកិច្ចរបស់ខ្លួនស្របតាមច្បាប់
- ចាត់វិធានការបង្ការ និងទប់ស្កាត់នូវរាល់សកម្មភាពទាំងឡាយណាដែលបំពានលើគោលការណ៍រក្សាការសម្ងាត់នៃព័ត៌មានរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត
- ត្រួតពិនិត្យ គ្រប់គ្រង និងអនុវត្តដោយផ្ទាល់នូវរាល់ដំណើរការ និងជំហាននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ទទួលធ្វើសម្ភាសន៍ និងពិនិត្យលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត ព្រមទាំងធ្វើការសម្រេចអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត និងសម្រេចយល់ព្រម ឬបដិសេធការសុំចុះឈ្មោះបោះឆ្នោត
- ទទួលធ្វើសម្ភាសន៍ និងពិនិត្យលក្ខខណ្ឌ និងសម្រេចចុះឈ្មោះបោះឆ្នោតចំពោះអ្នកផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ឬកែតម្រូវទិន្នន័យចំពោះអ្នក

ស្នើសុំកែតម្រូវទិន្នន័យជីវប្រវត្តិ (ប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ឬផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត) ឬធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (ថតរូប ផ្តិតមេដៃ)

- បំពេញសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)
- ធានាថា បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ត្រូវបានរៀបចំតាមភូមិនីមួយៗក្នុងឃុំ សង្កាត់ និងធានាថា មានអ្នកបោះឆ្នោតមិនលើសពី ៧៥០ (ប្រាំពីររយហាសិប) នាក់
- សហការជាមួយអនុប្រធាន ក.ច.ប ពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ជាមួយឯកសារសំអាងដែល លធ.ខប បានបញ្ជូនមក
- ដោះស្រាយជាបន្ទាន់នូវរាល់ការតវ៉ា និងការជំទាស់ចំពោះការរំលោភនានានៅក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ចូលរួមបំភ្លឺក្នុងរាល់ការប្រជុំសម្រេចរបស់ កបឃ.ស ដោះស្រាយពាក្យបណ្តឹងតវ៉ា និងអនុវត្តតាមការសម្រេចរបស់ កបឃ.ស និងតាមសមត្ថកិច្ចរបស់ខ្លួន
- ធានាថា ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានការបញ្ជាក់ទទួលស្គាល់បានសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់
- ស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬអាជ្ញាធរមានសមត្ថកិច្ចឱ្យនាំខ្លួនជនទាំងឡាយណាដែលបង្កការអុកឡុក ការរំខាន ឬការធ្វើសកម្មភាពផ្ទុយពីការកំណត់របស់ ច.ប.ត.រ ច.ប.ឃ.ស ច.រ.ច.ប ឬ ប.ន.ព.ច
- សំណូមពរភ្នាក់ងារសង្គ្រោះឱ្យជួយដល់ព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាព ឬជនទាំងឡាយណាដែលទទួលរងគ្រោះដោយមូលហេតុណាមួយក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត
- រាយការណ៍ជូន គ.ជ.ប តាមរយៈ កបឃ.ស និង លធ.ខប នូវរាល់ហេតុការណ៍ដែលកើតមានក្នុងដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដើម្បីសម្របសម្រួលដោះស្រាយបញ្ហា
- អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ប.ន.ព.ច និងតាមការប្រគល់ភារកិច្ចរបស់ គ.ជ.ប។

## ខ. តួនាទី និងភារកិច្ចរបស់អនុប្រធាន ក.ច.ប

អនុប្រធាន ក.ច.ប មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជួយប្រធាន ក.ច.ប ក្នុងការធ្វើគំរូប្លង់ និងធានាថាការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានសម្អាត និងថែរក្សាសុវត្ថិភាពបានល្អ
- ជួយប្រធាន ក.ច.ប ក្នុងការត្រួតពិនិត្យ និងការគ្រប់គ្រងបរិមាណ គុណភាពសម្ភារបរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត
- ថែរក្សាសុវត្ថិភាពសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ រួចហែក និងប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ទីលំនៅ (ប្រសិនបើមាន) ជូនទៅការីកុំព្យូទ័រ សម្រាប់អ្នកសុំចុះឈ្មោះបោះឆ្នោតថ្មី ឬបំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ) (ករណីអ្នកដែលធ្លាប់បានចុះឈ្មោះនៅឃុំ សង្កាត់ផ្សេង ផ្លាស់លំនៅឋានចូលថ្មី) តាមការកំណត់របស់ គ.ជ.ប
- បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ បន្ទាប់មកហែកបង្កាន់ដៃនេះ ព្រមទាំងដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) កិបភ្ជាប់ជាមួយបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលត្រូវបញ្ជូនមក គ.ជ.ប និងប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ទីលំនៅជូនការីកុំព្យូទ័រ
- សហការជាមួយប្រធាន ក.ច.ប ពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតជាមួយឯកសារសំអាងដែល លធ.ខប បានបញ្ជូនមក
- ថែរក្សាទុកជាឯកសារនូវរាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) ដោះស្រាយលើពាក្យបណ្តឹងតវ៉ា ដែលចេញដោយ កបឃ.ស និងឯកសារពាក់ព័ន្ធផ្សេងទៀតមួយមុខ ១ច្បាប់ៗ

- សហការជាមួយសមាជិក ក.ច.ប ដែលជាការីកុំព្យូទ័របញ្ជូនទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតដែលបានបញ្ចូលក្នុងកម្មវិធីកុំព្យូទ័ររួច តាមអ៊ីនធឺណិតជារៀងរាល់ថ្ងៃ ឬតាមរយៈគ្រូបង្គោលប្រចាំក្រុង ស្រុក ខណ្ឌ ករណីគ្មានសេវាអ៊ីនធឺណិតមកនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត (ន.គ.ទ.ប) ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតាមភូមិទាំងអស់ក្នុងឃុំ សង្កាត់
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ (ទ.១០២៩) និងរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ព្រមទាំងរបាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) នៅពេលដែលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់
- ធានាក្នុងការផ្ទៀងផ្ទាត់ និងការវេចខ្ចប់ដោយឡែកតាមការិយាល័យបោះឆ្នោតនីមួយៗ នូវរាល់ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ការលុបឈ្មោះ និងការប្តឹងតវ៉ា ព្រមទាំងគល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើ ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ និងសម្ភារ បរិក្ខារ និងឯកសារដែលនៅសល់ផ្សេងទៀតជូន លធ.ខប
- ចូលរួមជាមួយប្រធាន ក.ច.ប បំភ្លឺក្នុងរាល់ការប្រជុំសម្រេចរបស់ កបឃ.ស ដោះស្រាយពាក្យបណ្តឹងតវ៉ា
- អនុវត្តការងារដទៃទៀត ដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ប.ន.ព.ច និងតាមការប្រគល់ភារកិច្ចរបស់ គ.ជ.ប។

**គ. តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជាការីកុំព្យូទ័រ**

ការីកុំព្យូទ័រ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជួយប្រធាន ក.ច.ប ក្នុងការធ្វើគំរូប្លង់ និងធានាថាការិយាល័យចុះឈ្មោះបោះឆ្នោតត្រូវបានសម្អាត និងថែរក្សាសុវត្ថិភាពបានល្អ
- ជួយប្រធាន ក.ច.ប ក្នុងការត្រួតពិនិត្យ និងការគ្រប់គ្រងបរិមាណ និងគុណភាពសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត
- ជួយអនុប្រធាន ក.ច.ប ក្នុងការថែរក្សាសុវត្ថិភាពសម្ភារ បរិក្ខារ និងឯកសារចុះឈ្មោះបោះឆ្នោត មុនថ្ងៃចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងបន្តពិនិត្យតាមដាន នៅពេលបញ្ឈប់ដំណើរការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃនីមួយៗ

- ត្រូវម្ចាស់ការក្នុងការដំឡើងកុំព្យូទ័រ និងបរិក្ខារបំពាក់ រួមនឹងអ៊ីនធឺណិត សម្រាប់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ
- ជ្រើសរើសយកឈ្មោះភូមិ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោត បន្ទាប់មកធ្វើតេស្តស្នាមមេដៃទាំងសងខាង ថត អ.ខ ឬ ឯ.អ ជ្រើសរើសប្រវត្តិចុះឈ្មោះបោះឆ្នោត ជ្រើសរើសប្រភេទឯកសារចុះឈ្មោះបោះឆ្នោត បញ្ចូលលេខ អ.ខ ឬ ឯ.អ បញ្ចូលអត្តលេខអ្នកបោះឆ្នោតដែលមានក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និងបញ្ចូលទិន្នន័យផ្សេងទៀត ដែលបានរៀបចំរួចក្នុងកម្មវិធីកុំព្យូទ័រ សម្រាប់អ្នកសុំចុះឈ្មោះបោះឆ្នោតថ្មី ផ្ទេរ ឬ/និងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ ក្នុងបញ្ជីបោះឆ្នោតតាមកម្មវិធីដែលបានរៀបចំរួច សម្រាប់អ្នកផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី អ្នកស្នើសុំកែតម្រូវ ឬធ្វើបច្ចុប្បន្នភាពតាមការកំណត់របស់ គ.ជ.ប
- ផ្ទេរឈ្មោះ និងទិន្នន័យអ្នកសុំប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ទៅការិយាល័យបោះឆ្នោតថ្មីក្នុងភូមិដែលគាត់រស់នៅ តាមការកំណត់ក្នុងបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨)
- ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើស្កេនន័រស្នាមម្រាមដៃ (ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតណាដែលមានការលំបាកក្នុងការដាក់មេដៃ) ដើម្បីយកស្នាមម្រាមដៃទាំងសងខាងរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត ថតរូប និងថតឯកសារដែលបញ្ជាក់អំពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន) បញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដែលរក្សាទុកក្នុងកម្មវិធីកុំព្យូទ័ររួចហើយប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និង អ.ខ ឬ ឯ.អ ព្រមទាំងឯកសារពាក់ព័ន្ធជូនអ្នកសុំចុះឈ្មោះបោះឆ្នោតវិញ
- ស្នើសុំលុបឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតតាមកម្មវិធីកុំព្យូទ័រ ដោយភ្ជាប់មកជាមួយនូវឯកសារសំអាងមក គ.ជ.ប បន្ទាប់ពីប្រធាន និងអនុប្រធាន ក.ច.ប បានសម្រេចរួច
- ធានាថារាល់ទិន្នន័យ និងព័ត៌មានដែលបានកត់ត្រារួចនៅក្នុងកុំព្យូទ័រត្រូវរក្សាទុកឱ្យបាននូវការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពទិន្នន័យអត្តសញ្ញាណរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត
- ចូលរួមជាមួយអនុប្រធាន ក.ច.ប ចាត់ចែងបញ្ជូនទិន្នន័យអ្នកបោះឆ្នោតដែលបានបញ្ចូលក្នុងកម្មវិធីកុំព្យូទ័ររួច តាមអ៊ីនធឺណិតជារៀងរាល់ថ្ងៃទៅ ន.គ.ទ.ប ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតាមភូមិទាំងអស់ក្នុងឃុំ សង្កាត់

- ជួយអនុប្រធាន ក.ច.ប ក្នុងការធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ (ទ.១០២៩) និងរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) និងរបាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) នៅពេលដែលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់
- ជួយអនុប្រធាន ក.ច.ប ក្នុងការផ្ទៀងផ្ទាត់ ការវេចខ្ចប់កញ្ចប់ «ក» ស្បោង «ខ» និងរាល់សម្ភារ ឯកសារផ្សេងទៀតជូន លធ.ខប
- ជួយអនុប្រធាន ក.ច.ប ក្នុងការផ្ទៀងផ្ទាត់ ការវេចខ្ចប់ដោយឡែកតាមការិយាល័យបោះឆ្នោតនីមួយៗនូវរាល់ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការលុបឈ្មោះ និងការប្ដឹងតវ៉ា
- វេចខ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត(ទ.១០២២) ដែលបានប្រើហើយ (**ដាក់រួមគ្នាមិនចាំបាច់ញែកតាមការិយាល័យ**)
- វេចខ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ និងសម្ភារ បរិក្ខារ និងឯកសារដែលនៅសល់ផ្សេងទៀតជូន លធ.ខប
- អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ប.ន.ព.ច និងតាមការប្រគល់ភារកិច្ចរបស់ គ.ជ.ប។

**ឃ. តួនាទី និងភារកិច្ចរបស់សមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ក.ច.ប**

សមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ក.ច.ប មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ជួយការងារអនុប្រធាន ក.ច.ប ក្នុងការរៀបចំដំណើរការចុះឈ្មោះបោះឆ្នោត
- បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត(ទ.១០២២ មានអត្តលេខ) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ រួចហែក និងប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ទីលំនៅ (ប្រសិនបើមាន) ជូនទៅការីកុំព្យូទ័រ សម្រាប់អ្នកសុំចុះឈ្មោះបោះឆ្នោតថ្មី ឬបំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២គ្មានអត្តលេខ) (ករណីអ្នកផ្លាស់លំនៅឋានចូលថ្មីធ្លាប់បានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេង) តាមការកំណត់របស់ គ.ជ.ប

- បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ បន្ទាប់មកហែកបង្កាន់ដៃនេះ ព្រមទាំងដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) ភ្ជាប់ជាមួយបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលត្រូវបញ្ជូនមក គ.ជ.ប និងប្រគល់បង្កាន់ដៃនេះ និង អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ទីលំនៅជូនការីកុំព្យូទ័រ
- អនុវត្តការងារដទៃទៀតដែលតម្រូវដោយច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង ប.ន.ព.ច និងតាមការប្រគល់ភារកិច្ចរបស់ គ.ជ.ប ឬប្រធាន ក.ច.ប ឬ អនុប្រធាន ក.ច.ប ។

ង. ក្រុមចុះឈ្មោះបោះឆ្នោតពិសេស (ក.ច.ប.ព)

ក្រោយពេល ក.ច.ប ត្រូវបានរំសាយ ដើម្បីអនុវត្តសេចក្តីសម្រេចយល់ព្រមរបស់ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញលើពាក្យបណ្តឹងតវ៉ាទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត និងសេចក្តីសម្រេចយល់ព្រមរបស់ កបយ.ស គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញលើពាក្យបណ្តឹងតវ៉ាទៅនឹងបញ្ជីបោះឆ្នោតដំបូង គ.ជ.ប ត្រូវចាត់តាំងក្រុមចុះឈ្មោះបោះឆ្នោតពិសេស (ក.ច.ប.ព) ដើម្បីចុះឈ្មោះអ្នកប្តឹងតវ៉ាដែលត្រូវបានយល់ព្រមឱ្យចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត។

- ក.ច.ប.ព មានសមាសភាពប្រធាន ១ (មួយ)រូប សមាជិក ១ (មួយ)រូប ជាមន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប និងអនុប្រធាន ជាស្មៀនឃុំ សង្កាត់ពាក់ព័ន្ធ
- ក.ច.ប.ព ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងជំហានទី២ និងជំហានទី៣ នៃការចុះឈ្មោះបោះឆ្នោត
- បន្ទាប់ពីបញ្ចប់ការចុះឈ្មោះបោះឆ្នោត ទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវបញ្ជូនតាមអ៊ីនធឺណិតមក ន.គ.ទ.ប ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត
- ក.ច.ប.ព មានអាណត្តិបំពេញការងារតាមការកំណត់របស់ គ.ជ.ប។

## III. ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោត

### ១. លក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងដើម្បីមានសិទ្ធិចុះឈ្មោះបោះឆ្នោត

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋខ្មែរត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនិងមានអ.ខ។ ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋខ្មែរត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី១៨ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ឬត្រូវបោះឆ្នោត
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច។

ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវបង្ហាញខ្លួន និងមាន អ.ខ ឬ ឯ.អ នៅចំពោះមុខ ក.ច.ប ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅការិយាល័យចុះឈ្មោះបោះឆ្នោតដែលនៅសាលាឃុំ សង្កាត់ ឬតាមភូមិមួយចំនួន
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី១៨ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត
- មិនទាន់បានចុះឈ្មោះបោះឆ្នោត ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះបោះឆ្នោតនៅកន្លែងណាមួយក្នុងឃុំ សង្កាត់។

**ចំណាំ៖**

- ប្រជាពលរដ្ឋខ្មែរ កម្មករ សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល នាយ ឬពល នៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងបព្វជិតសាសនា ដែលកំពុងស្នាក់នៅ ឬកំពុងបំពេញការងារក្នុងឃុំ សង្កាត់ណាមួយសុទ្ធតែអាចសុំចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះដោយមានសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ឬលិខិតបញ្ជាក់ទីលំនៅដែលចេញដោយអាជ្ញាធរឃុំ សង្កាត់ ដើម្បីបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះឈ្មោះបោះឆ្នោត

- ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋាន ឬទីសំណាក់ច្រើនជាងមួយកន្លែង ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដែលជាទីតាំងនៃជីវភាពរស់នៅជាក់ស្តែងរបស់ខ្លួន ដើម្បីចុះឈ្មោះបោះឆ្នោត
- ប្រជាពលរដ្ឋខ្មែរម្នាក់ៗត្រូវមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់។ ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ដោយ គ.ជ.ប ចំពោះជនណាដោយទុច្ចរិតព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ។

## ២. ឯកសារសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត

ឯកសារចម្បងសម្រាប់ប្រើប្រាស់ក្នុងការសុំចុះឈ្មោះបោះឆ្នោត គឺ អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ។

**អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ**






៣. គំរូប្លង់ការិយាល័យចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦



# គំរូប្លង់ការិយាល័យចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់ ដែលមានសមាជិក គ.ច.ប បន្ថែម

គ.ជ.ប



## IV. ដំណើរប្រព្រឹត្តទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

កបឃ.ស និង ក.ច.ប ត្រូវចាត់ចែងគ្រប់គ្រង និងរៀបចំការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាម ច.ប.ត.វ ច.ប.ឃ.ស ច.វ.ច.ប និង ប.ន.ព.ច នេះ។ មេភូមិ និង ក.ច.ប ត្រូវជួយផ្សព្វផ្សាយបំផុស និងលើកទឹកចិត្តប្រជាពលរដ្ឋកំពុងរស់នៅក្នុងឃុំ សង្កាត់ ឱ្យមកពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅសាលាឃុំ សង្កាត់ ឬនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់។

- **អ្នកមកសុំចុះឈ្មោះបោះឆ្នោតគឺជា៖**
  - ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោត
  - ប្រជាពលរដ្ឋខ្មែររស់នៅក្នុងឃុំ សង្កាត់ ដែលមានអាយុ ១៨ ឆ្នាំឡើង គិតដល់ **ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)**
  - ប្រជាពលរដ្ឋខ្មែរដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី។
- **អ្នកមកស្នើសុំកែតម្រូវទិន្នន័យជីវប្រវត្តិគឺជា៖**

  ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ រួចហើយ ប៉ុន្តែមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ (ប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ឬផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត) ក្នុងបញ្ជីបោះឆ្នោត។
- **អ្នកមកស្នើសុំធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រគឺជា៖**

  ប្រជាពលរដ្ឋខ្មែរដែលបានចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ ដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ (ថតរូប ផ្តិតមេដៃ) ក្នុងបញ្ជីបោះឆ្នោតពីមុនមក។
- **ការលុបឈ្មោះអ្នកបានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតគឺ៖**

  ប្រជាពលរដ្ឋខ្មែរដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ដែលបានទទួលមរណភាព ហើយត្រូវបានសមាជិកគ្រួសាររាយការណ៍ផ្ទាល់ជូន ក.ច.ប ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ដើម្បី ក.ច.ប អនុវត្តនីតិវិធីបន្ត។

## ១. សម្ភារ បរិក្ខារ និងកុំព្យូទ័រសម្រាប់ការចុះឈ្មោះបោះឆ្នោត

សម្ភារ បរិក្ខារ និងកុំព្យូទ័រសម្រាប់ការចុះឈ្មោះបោះឆ្នោតតាមកម្មវិធីកុំព្យូទ័ររួមមាន៖


កុំព្យូទ័រយួរដៃ និងថ្ពាំងសាកថ្ម


Power Bank


មៅ (Mouse) និងទ្រនាប់មៅ (Mouse Pad)


ឧបទស្សន៍កុំព្យូទ័រទី២


ស្កេននរស្នាមម្រាមដៃ


កាមេរ៉ាថតរូប


Portable Scanner 1 set


ម៉ូដឹម (Modem)


USB Flash Drive


USB HUB


Type-C Hub


Type-C Converter


SD Card


ផ្ទាំងក្រណាត់ពណ៌ប្រផេះ


ព្រីភ្លើង


ម៉ាស៊ីនភ្លើង


ខ្សែ Network


Switch


កាបូបស្ពាយ


កេសអាលុយមីញ៉ូម និងសោសុវត្ថិភាព



ស្រោមសំបុត្រដាក់លេខសម្ងាត់

## ២. ជំហានទាំង៣ នៃការចុះឈ្មោះបោះឆ្នោត

ការចុះឈ្មោះបោះឆ្នោត ការកែតម្រូវទិន្នន័យជីវប្រវត្តិ ការធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត នៅតាមឃុំ សង្កាត់ ត្រូវធ្វើឡើងតាមកម្មវិធីកុំព្យូទ័រ និងបញ្ជូនទិន្នន័យពីឃុំ សង្កាត់ មក គ.ជ.ប តាមអ៊ីនធឺណិត។

ក.ច.ប ត្រូវអនុវត្តការចុះឈ្មោះបោះឆ្នោតតាមនីតិវិធីដូចបញ្ជាក់ក្នុងជំហានទាំង៣ និងករណីផ្សេងៗដូចខាងក្រោម៖

**–ជំហានទី១**

| | |
|---|---|
| ប្រធាន ក.ច.ប ត្រូវ៖ | - ផ្ញើសម្ភាសន៍អ្នកសុំចុះឈ្មោះបោះឆ្នោត<br>- សាកសួរព័ត៌មានគាត់ថា៖<br>○ តើអ្នកមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ឬទេ?<br>○ តើអ្នកបានចុះឈ្មោះបោះឆ្នោតហើយឬនៅ? |
| ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងមិនទាន់បានចុះឈ្មោះបោះឆ្នោត ប្រធាន ក.ច.ប ត្រូវ៖ | - ពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដូចខាងក្រោម៖<br>○ ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ<br>○ មានអាយុ ១៨ ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)<br>○ មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះបោះឆ្នោត ឬត្រូវបោះឆ្នោត។<br>- ជម្រាបអ្នកសុំចុះឈ្មោះឱ្យទៅជួបអនុប្រធាន ក.ច.ប ដើម្បីបន្តនីតិវិធីចុះឈ្មោះបោះឆ្នោតតាមជំហានបន្តបន្ទាប់ (ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោត បានបំពេញគ្រប់លក្ខខណ្ឌកំណត់)។ |
| ករណីអ្នកសុំចុះឈ្មោះបោះឆ្នោត ពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ប្រធាន ក.ច.ប ត្រូវ៖ | ចេញសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយបញ្ជាក់ពីមូលហេតុ និងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោត មិនបានបំពេញ។ |

**–ជំហានទី២**

| | |
|---|---|
| ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីសុំចុះឈ្មោះបោះឆ្នោតអនុប្រធាន ក.ច.ប ឬសមាជិក ក.ច.ប ដែលជួយការងារអនុប្រធាន ក.ច.ប ត្រូវ ៖ | - សួរតើទីលំនៅ នៅភូមិណា ដើម្បីកំណត់បញ្ចូលឈ្មោះទៅក្នុងការិយាល័យ បោះឆ្នោតក្នុងភូមិនោះ<br>- បំពេញទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ) ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ ចុះហត្ថលេខាឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះ រវាងគល់ទម្រង់ និងបង្កាន់ដៃ<br>- ប្រគល់ អ.ខ ឬ ឯ.អ និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ទៅការីកុំព្យូទ័រ និងណែនាំអ្នកសុំចុះឈ្មោះបោះឆ្នោតនោះឱ្យទៅជួបការីកុំព្យូទ័រ។ |

– ជំហានទី៣

ការីកុំព្យូទ័រ ត្រូវ៖

បញ្ចូលទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រដោយផ្អែកតាម អ.ខ ឬ ឯ.អ និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដូចខាងក្រោម៖

- ជ្រើសយកឈ្មោះភូមិ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតទៅតាមភូមិអ្នកសុំចុះឈ្មោះបោះឆ្នោត
- ជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតជាមុន បន្ទាប់មកតេស្តស្នាមមេដៃទាំងសងខាង។ ចំពោះអ្នកពិការដៃម្ខាង ឬទាំងសងខាង ឬគ្មានស្នាមម្រាមដៃ ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់ដំណើរការកម្មវិធី
- ថត អ.ខ ឬ ឯ.អ
- ជ្រើសរើសប្រវត្តិចុះឈ្មោះបោះឆ្នោត (មិនទាន់បានចុះឈ្មោះបោះឆ្នោត ឬបានចុះឈ្មោះឆ្នាំកន្លងមក)
- ជ្រើសរើសយកប្រភេទឯកសារសម្រាប់ប្រើចុះឈ្មោះបោះឆ្នោត (អ.ខ ឬ ឯ.អ)
- បញ្ចូលលេខ អ.ខ ឬ ឯ.អ
- បញ្ចូលអត្តលេខអ្នកបោះឆ្នោតដែលមាននៅក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២)
- បញ្ចូលនាមត្រកូល នាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត
- បញ្ចូលលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់
- ជ្រើសរើសភូមិឧបសម្ព័ន្ធ (ប្រសិនបើមាន)
- ជ្រើសរើសស្ថានភាពពិការភាពរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត (ប្រសិនបើសាមីខ្លួនយល់ព្រម)
- ថតរូបអ្នកសុំចុះឈ្មោះបោះឆ្នោតចំពីមុខ
- ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើស្កេនន័រស្នាមម្រាមដៃ ដើម្បីយកស្នាមមេដៃសាមីខ្លួនទាំងសងខាងឆ្វេងចំនួន៤ដង និងស្តាំចំនួន៤ដង បញ្ចូលទៅក្នុងកម្មវិធីកុំព្យូទ័រ ដោយត្រូវយកស្នាមមេដៃឆ្វេងមុន។ ក្នុងករណីអ្នកសុំចុះឈ្មោះពិការមេដៃណាមួយ ឬទាំងសងខាងត្រូវយកស្នាមម្រាមដៃបន្តបន្ទាប់ជំនួស ហើយក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពិការដៃម្ខាង ត្រូវយកស្នាមមេដៃម្ខាងទៀតដែលមាន។ ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ត្រូវកត់ត្រាចូលក្នុងរបាយការណ៍ជូន គ.ជ.ប
- ថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន)។ ក្នុងការថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់នេះ ការីកុំព្យូទ័រត្រូវថតយកគ្រប់ទំព័រនៃសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ (ថតសន្លឹកដែលមានទិន្នន័យពាក់ព័ន្ធ) ឬលិខិតបញ្ជាក់ទីលំនៅ
- ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យពាក់ព័ន្ធរបស់គាត់ដែលបានបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២។

ការីកុំព្យូទ័រ ត្រូវៈ (ត)

ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់គាត់

- រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ។ ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតដែលមិនអាចផ្ដល់ស្នាមម្រាមដៃបាន ប្រធាន ក.ច.ប ត្រូវផ្ដល់សិទ្ធិសម្រាប់រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និង អ.ខ ឬ ឯ.អ ព្រមទាំងឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។

**ចំណាំៈ**

- ការីកុំព្យូទ័រ ត្រូវបើកអ៊ីនធឺណិត (ករណីមានអ៊ីនធឺណិត) ដើម្បីបញ្ជូនទិន្នន័យមក ន.គ.ទ.ប។
- ចំពោះឃុំ សង្កាត់ ដែលគ្មានអ៊ីនធឺណិត គ្រូប្រចាំក្រុង ស្រុក ខណ្ឌ គឺជាអ្នកសម្របសម្រួលជាមួយ ក.ច.ប ក្នុងការប្រមូលទិន្នន័យ (File Backup) ដែលត្រូវរក្សាទុកក្នុងផ្លាសដ្រាយ (Flash Drive) ដោយមានបង្កប់ពាក្យសម្ងាត់ មិនអាចបើកមើល ឬកែទិន្នន័យទាំងនោះបានទៅតំបន់ដែលមានអ៊ីនធឺណិត ដើម្បីបញ្ជូនទិន្នន័យទាំងនោះមក ន.គ.ទ.ប។
- នៅរៀងរាល់ថ្ងៃ ពេលបញ្ចប់ការចុះឈ្មោះបោះឆ្នោតតាមថ្ងៃនីមួយៗ អនុប្រធាន ក.ច.ប និងការីកុំព្យូទ័រត្រូវត្រួតពិនិត្យឱ្យប្រាកដថា លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃ ត្រូវបានបញ្ជូនតាមអ៊ីនធឺណិតមក ន.គ.ទ.ប រួចរាល់ហើយ។
- នៅពេលផ្ទៀងផ្ទាត់ ត្រូវប្រៀបធៀបចំនួនសរុបនៃបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និងចំនួនទិន្នន័យសរុបដែលបានបញ្ជូន។
- បន្ទាប់មកត្រូវបំពេញរបាយការណ៍ស្ដីពីលទ្ធផលនៃការចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ (ទ.១០២៩) តាមការិយាល័យបោះឆ្នោតចំនួន ២ច្បាប់ ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយទិន្នន័យ (ទ.១០២៩) ក្នុងកម្មវិធីកុំព្យូទ័រ ព្រមទាំងបិទផ្សាយរបាយការណ៍នេះ នៅមុខការិយាល័យចុះឈ្មោះបោះឆ្នោតចំនួន ១ច្បាប់ និងរក្សាទុកជាឯកសារ ១ច្បាប់។

**៣. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់ពុំមាន អ.ខ ឬមាន អ.ខ ប៉ុន្តែពុំមានលក្ខខណ្ឌគ្រប់គ្រាន់ ប្រធាន ក.ច.ប ត្រូវចេញសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ និងត្រូវណែនាំអ្នកសុំចុះឈ្មោះបោះឆ្នោតតាមករណីដូចតទៅៈ

ក. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពុំមាន អ.ខ

សូមអ្នកទៅរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបំពេញបែបបទផ្តល់ អ.ខ ជូន។ ទន្ទឹមនេះ សូមអ្នកទៅបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ ដែលអ្នកត្រូវចុះឈ្មោះបោះឆ្នោត ចាប់ពីថ្ងៃទី៧ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦ ដោយនាំយកមកជាមួយនូវសំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬព្រះរាជក្រឹត្យ ឬសេចក្តីចម្លងព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថា សាមីខ្លួននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ឬឯកសារភស្តុតាងផ្លូវការដែលបញ្ជាក់ថា សាមីខ្លួនកើតមកពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ និងនាំសាក្សី២រូប ដែលមានសិទ្ធិបោះឆ្នោត មានលំនៅឋាន ឬទីសំណាក់ពិតប្រាកដក្នុងឃុំ សង្កាត់ ទៅជាមួយ រួមជាមួយរូបថតសាមីខ្លួន ទំហំ ៣×៤ ចំនួន ២សន្លឹក ដើម្បីអាជ្ញាធរឃុំ សង្កាត់ បំពេញបែបបទផ្តល់ ឯ.អ ជូន។

ប្រសិនបើអ្នកបានទទួល ឯ.អ នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួប ក.ច.បវិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

## លិខិតស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**លិខិតស្នើសុំ**
**ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ..............................ភេទ........សញ្ជាតិ........កើតនៅថ្ងៃទី.........ខែ..........ឆ្នាំ..................
មានលំនៅឋាន ឬទីសំណាក់លេខ............ផ្លូវ............ភូមិ...........................ឃុំ សង្កាត់..............................
ក្រុង ស្រុក ខណ្ឌ..........................រាជធានី ខេត្ត..........................។

**រួមនឹងសាក្សី**

ឈ្មោះ..................................ភេទ.........សញ្ជាតិ...........កើតនៅថ្ងៃទី........ខែ...........ឆ្នាំ..................និង
ឈ្មោះ..................................ភេទ.........សញ្ជាតិ...........កើតនៅថ្ងៃទី........ខែ...........ឆ្នាំ.......................
ដែលមានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ជាមួយ ដែលធានាថា ពិតជាស្គាល់ខ្ញុំបាទ/នាងខ្ញុំ ប្រាកដមែន និងទទួលខុសត្រូវតាមច្បាប់ជាធរមាន ចំពោះការធានានេះ ។

**គោរពជូន**

លោក លោកស្រីមេឃុំ ចៅសង្កាត់.............................

កម្មវត្ថុ: សំណើសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ។

សេចក្តីដូចបានជម្រាបជូនខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមជម្រាប លោក លោកស្រីមេឃុំ ចៅសង្កាត់ ថានៅពេលចុះឈ្មោះបោះឆ្នោត ខ្ញុំបាទ/នាងខ្ញុំមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ☐ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ ខ្ញុំបាទ/នាងខ្ញុំ បានបាត់ ឬខូច ☐ ។

អាស្រ័យហេតុនេះសូមលោក លោកស្រីមេឃុំ ចៅសង្កាត់ចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតឱ្យ ខ្ញុំបាទ/នាងខ្ញុំ ដោយអនុគ្រោះ ។

..........ថ្ងៃទី...........ខែ...........ឆ្នាំ...........

ស្នាមមេដៃសាក្សីទី១ ស្នាមមេដៃសាក្សីទី២ ស្នាមមេដៃអ្នកស្នើសុំ

ឈ្មោះ.......................... ឈ្មោះ.......................... ឈ្មោះ..........................

**ចំណាំ** : - ត្រូវបង្ហាញជូនលោកលោកស្រីមេឃុំ ចៅសង្កាត់នូវ សំបុត្រកំណើតច្បាប់ដើមឬសេចក្តីចម្លងសំបុត្រកំណើតច្បាប់ដើម ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរតាមការទាមទារសញ្ជាតិខ្មែររបស់ជនបរទេស ឬព្រះរាជក្រឹត្យផ្តល់សញ្ជាតិដោយសញ្ជាតូបនីយកម្មដល់ជនបរទេស ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថា សាមីខ្លួននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ឬឯកសារភស្តុតាងផ្លូវការដែលបញ្ជាក់ថា សាមីខ្លួនកើតមកពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ។

- ត្រូវផ្តិតមេដៃនៅមុខមេឃុំ ចៅសង្កាត់ ។

# ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត




ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ប៉ុន្តែអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត និងមិនបានយកមកជាមួយនូវសៀវភៅស្នាក់នៅច្បាប់ដើម ឬ សៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់

- សូមអ្នកទៅយកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ ដែលត្រូវស្នើសុំចុះឈ្មោះបោះឆ្នោត
- ប្រសិនបើអ្នកបានទៅយកសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើម ដែលមានបញ្ជាក់ការស្នាក់នៅរបស់ខ្លួនក្នុងឃុំ សង្កាត់ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួប ក.ច.ប វិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

## អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ



ឬ

សៀវភៅស្នាក់នៅច្បាប់ដើម




សៀវភៅគ្រួសារច្បាប់ដើម




គ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ហើយអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនសុំចុះឈ្មោះបោះឆ្នោត និងគ្មានសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់នោះ

- សូមអ្នកទៅបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខមេឃុំ ចៅសង្កាត់ ដោយនាំទៅជាមួយនូវ អ.ខ លិខិតអនុញ្ញាតស្នាក់នៅបណ្ដោះអាសន្ន (ក៩) ចេញដោយប៉ុស្ដិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងសាក្សី ១រូប ដែលមានសិទ្ធិបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាមួយ (សាក្សីរូបនោះ ត្រូវនាំទៅជាមួយនូវឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់) ដើម្បីបំពេញបែបបទផ្ដល់លិខិតបញ្ជាក់ទីលំនៅជូន
- ប្រសិនបើអ្នកបានទទួលលិខិតបញ្ជាក់ទីលំនៅ ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត អ្នកត្រូវត្រឡប់មកជួប ក.ច.ប វិញ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

| អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | | លិខិតបញ្ជាក់ទីលំនៅ |
|---|---|---|
|  | + |  |



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត..........
ក្រុង ស្រុក ខណ្ឌ..........
ឃុំ សង្កាត់..........

លេខ: 000000000

**លិខិតបញ្ជាក់ទីលំនៅ**

យោងប្រកាសលេខ..... ប្រ.ក ចុះថ្ងៃទី.... ខែ...... ឆ្នាំ២០១... របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត។

យើងមេឃុំ ចៅសង្កាត់..........សូមបញ្ជាក់ថា៖
- ឈ្មោះ..........ភេទប្រុស ☐ ស្រី ☐
- កើតនៅថ្ងៃ.....ទីខែ.....ឆ្នាំ..... ពិតជាមានលំនៅឋានឬទីសំណាក់
- លេខ.....ផ្លូវ.....ភូមិ.....ឃុំ សង្កាត់.....
ក្រុង ស្រុក ខណ្ឌ.....រាជធានី ខេត្ត.....ពិតប្រាកដមែន។

លិខិតបញ្ជាក់ទីលំនៅនេះធ្វើឡើងដោយផ្អែកលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានលេខ..........និងការឆ្លើយបញ្ជាក់របស់សាមីខ្លួន និងសាក្សី៖
- ឈ្មោះ..........ភេទប្រុស ☐ ស្រី ☐
- កើតនៅថ្ងៃទី.....ខែ.....ឆ្នាំ.....មានលំនៅឋានឬទីសំណាក់
លេខ.....ផ្លូវ.....ភូមិ.....ឃុំ សង្កាត់.....
ក្រុង ស្រុក ខណ្ឌ.....រាជធានី ខេត្ត.....
ពិតជាត្រឹមត្រូវ និងទទួលខុសត្រូវចំពោះមុខច្បាប់ ។

លិខិតបញ្ជាក់ទីលំនៅនេះ ចេញជូនសាមីខ្លួន សម្រាប់គោលដៅនៃការសុំចុះឈ្មោះបោះឆ្នោតតាមការកំណត់នៃច្បាប់បោះឆ្នោត។

ធ្វើនៅថ្ងៃទី.....ខែ.....ឆ្នាំ.....

ស្នាមមេដៃ　　　　មេឃុំ ចៅសង្កាត់

សាមីខ្លួន　　　　សាក្សី

### ៨. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតឆ្លើយថា គាត់ធ្លាប់ចុះឈ្មោះបោះឆ្នោតម្តងរួចហើយ ប្រធាន ក.ច.ប ត្រូវសួរបន្តថា តើអ្នកធ្លាប់ចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ណា? ឆ្នាំណា ?

#### ក. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេង

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ នៅក្នុងឃុំ សង្កាត់ផ្សេងក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ ប្រធាន ក.ច.ប ត្រូវបន្តនីតិវិធីចុះឈ្មោះបោះឆ្នោត ដូចខាងក្រោម៖

❖ ប្រធាន ក.ច.ប ត្រូវ៖
  - ពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោតដូចខាងក្រោម៖
    ☛ ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ

- ☛ មានអាយុ១៨ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
- ☛ មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវសុំចុះឈ្មោះបោះឆ្នោត។

- ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យទៅជួបអនុប្រធាន ក.ច.ប ហើយ អនុប្រធាន ក.ច.ប ត្រូវហុច អ.ខ ឬ ឯ.អ ជូនការីកុំព្យូទ័រស្វែងរកប្រវត្តិចុះឈ្មោះបោះឆ្នោត មុននឹងបន្តនីតិវិធីចុះឈ្មោះបោះឆ្នោត។

❖ **អនុប្រធាន ក.ច.ប ត្រូវអនុវត្តដូចខាងក្រោម ៖**

- **ករណីរកពុំឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោត**

ក.ច.ប ត្រូវអនុវត្តតាមនីតិវិធីចុះឈ្មោះបោះឆ្នោត ដូច មានបញ្ជាក់ក្នុងជំហានទី២ និងជំហានទី៣ នៃសៀវភៅណែនាំនេះ។

- **ករណីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយនៃឃុំ សង្កាត់ផ្សេង**

អនុប្រធាន ក.ច.ប ត្រូវសួរទីលំនៅក្នុងភូមិបច្ចុប្បន្ន ដើម្បីកំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោត និងត្រូវបំពេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ) ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ ចុះហត្ថលេខា ឈ្មោះ និងបោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត។ បន្ទាប់មកត្រូវប្រគល់ អ.ខ ឬ ឯ.អ និងឯកសារពាក់ព័ន្ធទៅការីកុំព្យូទ័រ និងណែនាំអ្នកសុំចុះឈ្មោះបោះឆ្នោតនោះឱ្យទៅជួបការីកុំព្យូទ័រ។

❖ **ការីកុំព្យូទ័រ ត្រូវអនុវត្តដូចខាងក្រោម ៖**

- ស្វែងរកឈ្មោះ និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះតាមរយៈអត្តលេខ ទ.១០២២ ចាស់ (ប្រសិនបើមាន) លេខ អ.ខ លេខ ឯ.អ ឬតាមរយៈនាមត្រកូល និងនាមខ្លួននៅតាមឃុំ សង្កាត់ នៃរាជធានី ខេត្ត ដែលគាត់បានចុះឈ្មោះបោះឆ្នោត
- បន្ទាប់ពីទិន្នន័យបានបង្ហាញរួច ត្រូវធ្វើការផ្ទៀងផ្ទាត់រូបថតបន្ថែមទៀត។ ប្រសិនបើឈ្មោះ និងទិន្នន័យ ព្រមទាំងរូបថតរបស់សាមីខ្លួនត្រឹមត្រូវហើយ ការីកុំព្យូទ័រត្រូវធ្វើការទាញយកទិន្នន័យមួយចំនួន ដែលរួមមានអត្តលេខអ្នកបោះឆ្នោត លេខ អ.ខ ឬ ឯ.អ នាមត្រកូល និងនាមខ្លួន បន្ទាប់មកចុចលើប៊ូតុងផ្ទេរចូល
- ជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោត បន្ទាប់មកធ្វើតេស្តស្នាមមេដៃទាំងសងខាង
- ជ្រើសរើសយកឈ្មោះភូមិ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោតទៅតាមអ្នកសុំចុះឈ្មោះបោះឆ្នោត
- ថត អ.ខ ឬ ឯ.អ

- កែតម្រូវលេខ អ.ខ ឬ ង.អ ប្រសិនបើករណីឯកសារចុះឈ្មោះបោះឆ្នោត មានការផ្លាស់ប្តូរ
- កែតម្រូវនាមត្រកូល នាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត ករណីទិន្នន័យចាស់មានកំហុស
- បញ្ចូល ឬកែតម្រូវលេខផ្ទះ ឈ្មោះផ្លូវ ក្រុម ឬភូមិឧបសម្ព័ន្ធ តាមអាសយដ្ឋានបច្ចុប្បន្ន
- ជ្រើសរើសស្ថានភាពពិការភាពអ្នកចុះឈ្មោះបោះឆ្នោត (ប្រសិនបើមាន)
- ថតរូបអ្នកសុំចុះឈ្មោះបោះឆ្នោតចំពីមុខ
- យកស្នាមមេដៃសាមីខ្លួនទាំងសងខាង ឆ្វេងចំនួន៤ដង និងស្តាំចំនួន៤ដង បញ្ចូលទៅក្នុងកម្មវិធីកុំព្យូទ័រ ដោយត្រូវយកស្នាមមេដៃឆ្វេងមុន។ ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពិការមេដៃណាមួយ ឬទាំងសងខាង ត្រូវយកស្នាមម្រាមដៃបន្តបន្ទាប់ជំនួស ហើយក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតពិការដៃម្ខាងត្រូវយកស្នាមមេដៃដែលមាន
- ថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន)។ ក្នុងការថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់នេះ ការីកុំព្យូទ័រត្រូវតែថតគ្រប់ទំព័រទាំងអស់នៃសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ (ថតសន្លឹកដែលមានទិន្នន័យពាក់ព័ន្ធ) ឬលិខិតបញ្ជាក់ទីលំនៅ
- ជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោតឱ្យពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យពាក់ព័ន្ធរបស់គាត់ដែលបានបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២។ ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ដើម្បីផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់គាត់
- បន្ទាប់មកត្រូវរក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ គ្មានអត្តលេខ) និង អ.ខ ឬ ង.អ ព្រមទាំងឯកសារពាក់ព័ន្ធ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។

**ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយនៅឃុំ សង្កាត់ផ្សេង ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតគាត់ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយនៅក្នុងឃុំ សង្កាត់ផ្សេង ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រធាន ក.ច.ប ត្រូវបន្តអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងជំហានទាំង៣ នៃការចុះឈ្មោះបោះឆ្នោត ដោយឱ្យអនុប្រធាន ក.ច.ប បំពេញឆ្នាំ និងគូសធិកសម្គាល់ក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ)

ដើម្បីបញ្ជាក់ពីករណីនេះ និងដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន)។

៥. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលយ៉ាងតិច ១០ឆ្នាំ

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឃុំ សង្កាត់នេះហើយមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោត ប្រធាន ក.ច.ប ត្រូវស្នើសុំគាត់ឱ្យបង្ហាញ អ.ខ ឬ ឯ.អ ដែលបានប្រើពេលចុះឈ្មោះបោះឆ្នោតពីមុនមក ដែលមានឈ្មោះ និងទិន្នន័យត្រឹមត្រូវ និងបង្ហាញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) (ប្រសិនបើមាន)។ ប្រសិនបើឯកសារដែលគាត់បង្ហាញត្រឹមត្រូវហើយ ប្រធាន ក.ច.ប ត្រូវបន្តអនុវត្តនីតិវិធីដូចខាងក្រោម៖

ក. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំប្ដូរការិយាល័យបោះឆ្នោត

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ តែមានបំណងស្នើសុំប្តូរការិយាល័យបោះឆ្នោតពីភូមិមួយទៅភូមិមួយទៀតក្នុងឃុំ សង្កាត់ដដែលដោយសារបានផ្លាស់ប្តូរទីលំនៅ ឬស្នើសុំប្តូរការិយាល័យបោះឆ្នោតមួយទៅការិយាល័យបោះឆ្នោតមួយទៀតក្នុងភូមិជាមួយ ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់ឱ្យអនុប្រធាន ក.ច.ប ៖
  - បំពេញទម្រង់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ
  - ហែកបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ប្រគល់ជូនការីកុំព្យូទ័រ
  - ដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) កិបភ្ជាប់ជាមួយគល់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលត្រូវបញ្ជូនមក គ.ជ.ប
  - ណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ។
- ចាត់ឱ្យការីកុំព្យូទ័រ៖
  - ទាញយកទិន្នន័យរបស់អ្នកស្នើសុំតាមរយៈស្នាមមេដៃ អត្តលេខ លេខ អ.ខ លេខ ឯ.អ ឬនាមត្រកូល និងនាមខ្លួន។ ប្រសិនបើមានទិន្នន័យបង្ហាញថាជាអ្នកស្នើសុំពិតប្រាកដ ការីកុំព្យូទ័រត្រូវផ្ទេរឈ្មោះ និងទិន្នន័យអ្នកស្នើសុំប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ទៅការិយាល័យបោះឆ្នោតថ្មីក្នុង

ភូមិដែលគាត់រស់នៅដូចបានកំណត់ក្នុងបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨)

- ជម្រាបអ្នកស្នើសុំឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួន ដែលបានបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២ រួចឱ្យអ្នកស្នើសុំផ្តល់ស្នាមមេដៃ ដើម្បីបញ្ជាក់ថាគាត់ពិតជាបានស្នើសុំប្តូរការិយាល័យបោះឆ្នោត។ ក្នុងករណី អ្នកស្នើសុំមិនអាចផ្តល់ស្នាមម្រាមដៃបានទេ ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិដើម្បីរក្សាទុកទិន្នន័យ
- ប្រគល់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) និងឯកសារពាក់ព័ន្ធឱ្យអ្នកស្នើសុំ។

**ខ. ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំកែតម្រូវទិន្នន័យ ឬ/និងផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត**

ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះរួចហើយក្នុងឃុំ សង្កាត់នេះ ប៉ុន្តែទិន្នន័យរបស់ខ្លួនដូចជាឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត កត់ត្រាមិនត្រឹមត្រូវ ឬទើបបានទទួល អ.ខ ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់អនុប្រធាន ក.ច.ប បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ជូនសាមីអ្នកស្នើសុំ។ បន្ទាប់មកត្រូវប្រគល់ អ.ខ ឬ ឯ.អ ទៅការីកុំព្យូទ័រ និងណែនាំអ្នកស្នើសុំនេះឱ្យទៅជួបការីកុំព្យូទ័រ។
- ចាត់ការីកុំព្យូទ័រ ឱ្យអនុវត្តដូចខាងក្រោម៖
  - ទាញយកទិន្នន័យរបស់អ្នកស្នើសុំតាមរយៈស្នាមមេដៃ អត្តលេខអ្នកបោះឆ្នោត លេខ អ.ខ លេខ ឯ.អ ឬនាមត្រកូល និងនាមខ្លួន។ ប្រសិនបើមានទិន្នន័យបង្ហាញថាជារបស់សាមីអ្នកស្នើសុំពិតប្រាកដការីកុំព្យូទ័រត្រូវកែតម្រូវទិន្នន័យតាមការស្នើសុំ ដោយផ្អែកលើ អ.ខ ឬ ឯ.អ ដែលបានប្រើពេលចុះឈ្មោះបោះឆ្នោតពីមុន ថតរូប និងស្កេនស្នាមម្រាមដៃបន្ថែមទៀតក្នុងកម្មវិធីកុំព្យូទ័រ។ ប្រសិនបើសុំប្តូរ អ.ខ ការីកុំព្យូទ័រត្រូវថត អ.ខ និងបញ្ចូលលេខ អ.ខ
  - ជម្រាបអ្នកសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ឈ្មោះ ឬ/និងទិន្នន័យរបស់គាត់ដែលបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២ រួចស្នើអ្នកសុំផ្តល់ស្នាមម្រាមដៃបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រ ដើម្បីបញ្ជាក់ថាគាត់ពិតជាបានស្នើសុំកែតម្រូវទិន្នន័យប្រាកដមែន។ ក្នុងករណីអ្នកស្នើសុំមិនអាចផ្តល់ស្នាមម្រាមដៃបានទេប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់រក្សាទុកឈ្មោះ ឬ/និងទិន្នន័យដែលបានកែតម្រូវ។
  - ប្រគល់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ឱ្យអ្នកស្នើសុំ។

គ. ករណីអ្នកបោះឆ្នោតស្នើសុំធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ

អ្នកបោះឆ្នោតដែលត្រូវអញ្ជើញមកធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ គឺអ្នកចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ ប៉ុន្តែទិន្នន័យជីវមាត្រ (រូបថត ស្នាមម្រាមដៃ) របស់ខ្លួនក្នុងបញ្ជីបោះឆ្នោតពុំធ្លាប់បានធ្វើបច្ចុប្បន្នភាពពីមុន ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់ឱ្យអនុប្រធាន ក.ច.ប បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និង កែតម្រូវទិន្នន័យ (ទ.១០២៨) ជូនសាមីអ្នកស្នើសុំ។ បន្ទាប់មកត្រូវប្រគល់ អ.ខ ទៅការីកុំព្យូទ័រ និងណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ
- ចាត់ការីកុំព្យូទ័រឱ្យថតរូប និងស្កេនស្នាមម្រាមដៃអ្នកស្នើសុំឡើងវិញ។

៦. ករណីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានទទួលមរណភាពក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត

ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រសិនបើមានរបាយការណ៍អំពីអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានទទួលមរណភាព ដោយមានឯកសារត្រឹមត្រូវ និងច្បាស់លាស់ ក.ច.ប ត្រូវរាយការណ៍ជូន កបឃ.ស ដើម្បីអនុវត្តនីតិវិធីស្រង់ឈ្មោះដាក់ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត (ទ.១០២៥) ហើយ ក.ច.ប ត្រូវអនុវត្តនីតិវិធីលុបឈ្មោះក្នុងកម្មវិធីកុំព្យូទ័រផ្អែកតាមបញ្ជីអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត (ទ.១០២៥) បន្ទាប់ពី កបឃ.ស បានប្រជុំសម្រេចរួចហើយ។ ករណីនេះ កបឃ.ស និង ក.ច.ប ត្រូវចាត់ចែងបញ្ជូនបញ្ជីឈ្មោះអ្នកទទួលមរណភាព និងឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់មក ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមរយៈ លធ.ឌប ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ។

៧. ការអនុវត្តរបស់ ក.ច.ប លើរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត

បន្ទាប់ពីបានទទួលរបាយការណ៍ស្តីពីការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ដោយមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ដែល លធ.ឌប បានបញ្ជូនមកដូចមានចែងក្នុងគំនូសទី១ នៃចំណុចទី៧

នៃចំណុចទីVIII ខាងក្រោមនេះ ព្រមទាំងរបាយការណ៍ដូចមានចែងក្នុងចំណុចទី៦ នៃចំណុចទីIV ខាងលើនេះ ក.ច.ប ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមករណីនីមួយៗ ដោយផ្អែកលើឯកសារសំអាង និងទិន្នន័យក្នុងកម្មវិធីកុំព្យូទ័រ។ ប្រធាន និងអនុប្រធាន ក.ច.ប ត្រូវ៖

- ធ្វើការពិនិត្យលើបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត ជាមួយឯកសារសំអាងឱ្យបានច្បាស់លាស់តាមករណីនីមួយៗ និងទិន្នន័យមួយចំនួនក្នុងបញ្ជីបោះឆ្នោតចុងក្រោយ ដូចជាលេខ អ.ខ នាមត្រកូល នាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតជាដើម
- ចាត់ការីកុំព្យូទ័រឱ្យធ្វើការផ្ទៀងផ្ទាត់បញ្ជីនេះ ជាមួយទិន្នន័យក្នុងកម្មវិធីកុំព្យូទ័របន្ថែមទៀត
- សម្រេចឱ្យការីកុំព្យូទ័រធ្វើការស្នើសុំលុបឈ្មោះអ្នកទាំងនោះតាមកម្មវិធីកុំព្យូទ័រដែលបានកំណត់ក្នុងអំឡុងពេលចាប់ផ្តើមរហូតដល់ថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ មក គ.ជ.ប ដោយភ្ជាប់មកជាមួយនូវឯកសារសំអាង។ ឯកសារសំអាងសម្រាប់ស្នើសុំលុបឈ្មោះអ្នកបោះឆ្នោតត្រូវមានតាមករណីដូចខាងក្រោម៖
    - ករណីអ្នកបោះឆ្នោតទទួលមរណភាព ត្រូវមានលិខិតមរណភាព ឬលិខិតបញ្ជាក់ការបូជា ឬការបញ្ចុះសព ឬលិខិតអះអាងថាអ្នកបោះឆ្នោតបានទទួលមរណភាពបញ្ជាក់ដោយក្រុមគ្រួសារ ឬអ្នកជិតខាងក្នុងភូមិដោយមានការផ្តិតមេដៃ និងមានការបញ្ជាក់ពីមេភូមិ និងមានការបញ្ជាក់ឯកភាពពីមេឃុំ ចៅសង្កាត់
    - ករណីអ្នកបោះឆ្នោតផ្លាស់ទីលំនៅចេញពីឃុំ សង្កាត់ ត្រូវមានលិខិតអនុញ្ញាតផ្លាស់ប្តូរទីលំនៅ "ក៦"
    - ករណីអ្នកបោះឆ្នោតត្រូវបានដកហូតសិទ្ធិបោះឆ្នោត ត្រូវមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច។

### ៨. បែបបទ និងនីតិវិធីនៃការផ្តល់ ឯ.អ

អនុលោមតាម ច.ប.ត.រ និងសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប អាជ្ញាធរឃុំ សង្កាត់ មានសិទ្ធិក្នុងការចេញ ឯ.អ ជូនប្រជាពលរដ្ឋខ្មែរដែលមិនទាន់មាន អ.ខ ឬ អ.ខ បានអស់សុពលភាព ឬមិនទាន់បានទទួល ឬ អ.ខ របស់ខ្លួនបានខូច ឬបាត់ ឬកែតម្រូវ តាមការស្នើសុំ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោត។

នីតិវិធីនៃការស្នើសុំ និងការចេញ ឯ.អ ត្រូវអនុវត្តផ្អែកតាមសេចក្តីណែនាំរួមរវាងក្រសួងមហាផ្ទៃ និង គ.ជ.ប។

មេឃុំ ចៅសង្កាត់ មានសមត្ថកិច្ចចេញ ឯ.អ ជូនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនតាមការស្នើសុំរបស់សាមីខ្លួនដោយមិនតម្រូវឱ្យបង់ថ្លៃឡើយ ដើម្បីយកទៅប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត។

រដ្ឋបាលឃុំ សង្កាត់ ឬជនណាដែលក្លែងបន្លំ ឯ.អ ឬចេញ ឯ.អ មិនបានត្រឹមត្រូវតាមបែបបទ និងនីតិវិធី ឬបង្កការអុកឡុក ការរំខានដល់ដំណើរការចេញ ឯ.អ ឬមិនព្រមចេញ ឯ.អ ជូនអ្នកស្នើសុំដែលបំពេញគ្រប់លក្ខខណ្ឌ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

បន្ទាប់ពីបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត គ.ជ.ប អាចធ្វើការត្រួតពិនិត្យនីត្យានុកូលភាព និងប្រសិទ្ធភាពនៃការរក្សាទុកសៀវភៅបញ្ជី ឯ.អ ដែលបានប្រើខ្លះហើយ និងដែលបានប្រើអស់នៅសល់គល់បញ្ជីនៅរដ្ឋបាលឃុំ សង្កាត់ ដើម្បីធានាឱ្យមានគណនេយ្យភាពនៃការប្រើប្រាស់ ឯ.អ នេះ។

### ៩.បែបបទ និងនីតិវិធីនៃការស្នើសុំ និងការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់

អ្នកសុំចុះឈ្មោះបោះឆ្នោត ដែលបានបង្ហាញ អ.ខ ប៉ុន្តែអាសយដ្ឋានក្នុង អ.ខ ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលសាមីខ្លួនកំពុងរស់នៅ ហើយសាមីខ្លួនពុំមានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ ដែលមានបញ្ជាក់ការស្នាក់នៅរបស់សាមីខ្លួនក្នុងឃុំ សង្កាត់ ដែលគាត់សុំចុះឈ្មោះបោះឆ្នោតនោះ មានសិទ្ធិស្នើសុំលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់សម្រាប់ប្រើប្រាស់ ក្នុងគោលដៅនៃការសុំចុះឈ្មោះបោះឆ្នោតពីអាជ្ញាធរឃុំ សង្កាត់ ។

នីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តដោយផ្អែកតាមប្រកាសរបស់ក្រសួងមហាផ្ទៃ។

មេឃុំ ចៅសង្កាត់ ជាតំណាងឱ្យអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្តនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅនេះ។ ក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមានត្រូវប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរជូនជំទប់ ឬចៅសង្កាត់រងតាមឋានានុក្រមឱ្យបំពេញការងារនេះជំនួស ។

មេឃុំ ចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រងដែលត្រូវបានប្រគល់សិទ្ធិពីមេឃុំ ចៅសង្កាត់ ឬជនណាដែលអនុវត្តមិនត្រឹមត្រូវ ឬល្មើសនឹងនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃនឹងត្រូវផ្តន្ទាទោសតាមច្បាប់ ។

## V. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត

### ១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ កបឃ.ស

អ្នកសុំចុះឈ្មោះបោះឆ្នោតដែលត្រូវបាន ក.ច.ប បដិសេធការសុំចុះឈ្មោះបោះឆ្នោត ឬតំណាងមានសិទ្ធិប្ដឹងតវ៉ាទៅ កបឃ.ស ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)។

❖ ការដាក់ និងការទទួលពាក្យបណ្ដឹងនៅ កបឃ.ស

អ្នកប្ដឹងត្រូវបំពេញពាក្យបណ្ដឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ រួចចុះហត្ថលេខា ឬផ្ដិតមេដៃដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្ដឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្ដឹងជំនួសខ្លួនបាន។ ពាក្យបណ្ដឹងត្រូវដាក់នៅ កបឃ.ស តាមការកំណត់។

- នៅពេលបានទទួលពាក្យបណ្ដឹង (ទ.១២០២) កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនមានជាអាទិ៍ដូចខាងក្រោម៖
  - ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬ/និងតំណាង
  - កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)។
- បន្ទាប់មកមេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវធ្វើកំណត់ហេតុសាកសួរពីអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខា មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសពីការមិនព្រមផ្ដិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ
- បន្ទាប់ពីបានពិនិត្យលើពាក្យបណ្ដឹង និងកំណត់ហេតុសាកសួរហើយឃើញថា៖
  - ពាក្យបណ្ដឹងមិនគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា «**ពាក្យបណ្ដឹងនេះបានដាក់ក្រោយរយៈពេលកំណត់ដូចមានចែងក្នុងមាត្រា៥៤ នៃ ច.ប.ត.រ ដែលជាហេតុធ្លោះសិទ្ធិក្នុងការប្ដឹងមក កបឃ.ស។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**»។ បន្ទាប់មកចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ។ ពាក្យបណ្ដឹង (ទ.១២០២) ប្រើប្រាស់ ដូចខាងក្រោម៖

**ទ.១២០២ ចំនួន ៣ច្បាប់**
- ១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ឧប ពាក់ព័ន្ធ
- ១ច្បាប់ រក្សាទុកជាឯកសារ។

- ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬតំណាងមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ ជាអាទិ៍ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវណែនាំអ្នកប្ដឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្ដឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្ដឹង ឬតំណាង មិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា «**ពាក្យបណ្ដឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ ឬមិនមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ ឬលិខិតប្រគល់សិទ្ធិមិនត្រឹមត្រូវ...**» បន្ទាប់មកចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ។ ពាក្យបណ្ដឹង (ទ.១២០២) ប្រើប្រាស់ដូចខាងក្រោម៖

**ទ.១២០២ ចំនួន ៣ច្បាប់**
- ១ច្បាប់ ផ្ញើជូនអ្នកប្ដឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ឧប ពាក់ព័ន្ធ
- ១ច្បាប់ រក្សាទុកឯកសារ។

- កម្មវត្ថុនៃពាក្យបណ្ដឹងមិនទាក់ទងនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិត្រូវចារបដិសេធលើពាក្យបណ្ដឹងគ្រប់ច្បាប់ថា «**ពាក្យបណ្ដឹងនេះពុំស្ថិតក្នុងដែនសមត្ថកិច្ចរបស់ កបឃ.ស ទេ។ ដូចនេះ កបឃ.ស មិនអាចទទួលពាក្យបណ្ដឹងនេះមកពិនិត្យ និងដោះស្រាយបានឡើយ**»។ បន្ទាប់មកចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ។ ពាក្យបណ្ដឹង (ទ.១២០២) ប្រើប្រាស់ដូចខាងក្រោម៖

**ទ.១២០២ ចំនួន ៣ច្បាប់**
- ១ច្បាប់ ជូនអ្នកប្ដឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ឧប ពាក់ព័ន្ធ
- ១ច្បាប់ រក្សាទុកឯកសារ។

- កម្មវត្ថុនៃពាក្យបណ្ដឹងទាក់ទងនឹងការសុំចុះឈ្មោះបោះឆ្នោត និងពាក្យបណ្ដឹងគោរពរយៈពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដី

សម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) និងមានព័ត៌មានចាំបាច់ និងមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវតាមច្បាប់ (ចំពោះសាមីខ្លួនមិនចូលខ្លួនប្តឹងផ្ទាល់) មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះកាលបរិច្ឆេទ ពេលវេលានៃការប្រជុំសម្រេច ហើយចុះហត្ថលេខា ឈ្មោះ បោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទលើពាក្យបណ្តឹងគ្រប់ច្បាប់។ ពាក្យបណ្តឹង (ទ.១២០២) ប្រើប្រាស់ដូចខាងក្រោម៖

**ទ.១២០២ ចំនួន ៣ច្បាប់**
- ១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ច្បាប់ បិទផ្សាយជាសាធារណៈនៅសាលាឃុំ សង្កាត់
- ១ច្បាប់ ទុកប្រើប្រាស់ក្នុងការប្រជុំសម្រេច។

❖ **ការដោះស្រាយពាក្យបណ្តឹងនៅ កបឃ.ស**

កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២) ដោយផ្អែកលើ៖

- មូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ តាមលក្ខខណ្ឌតម្រូវសម្រាប់ការចុះឈ្មោះបោះឆ្នោត
- មូលហេតុនៃការបដិសេធលើសេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩) របស់ ក.ច.ប។

**ចំណាំ៖**

☛ ការប្រជុំសម្រេចរបស់ កបឃ.ស ត្រូវយកសំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ទាំងមូល និងករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានក្រុមប្រឹក្សាប្រជុំសម្រេចមានឧត្តមានុភាព។

❖ **ករណីសម្រេចយល់ព្រមលើពាក្យបណ្តឹង**

- ធ្វើកំណត់ហេតុប្រជុំសម្រេច
- លេខាធិការអង្គប្រជុំសម្រេចត្រូវស្រង់សេចក្តីសម្រេចយល់ព្រមចេញពីកំណត់ហេតុប្រជុំសម្រេចដាក់ចូលក្នុងសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ច្បាប់ រួចចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ហើយបោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ប្រើប្រាស់ដូចខាងក្រោម៖

**ទ.១២០៣ ចំនួន ៣ច្បាប់**
- ១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ឧប ពាក់ព័ន្ធ
- ១ច្បាប់ រក្សាទុកជាឯកសារ។

- ចាត់ ក.ច.ប ឱ្យអនុវត្តការចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងជំហានទាំង៣នៃការចុះឈ្មោះបោះឆ្នោត។

❖ **ករណីសម្រេចបដិសេធលើពាក្យបណ្តឹង**

- ធ្វើកំណត់ហេតុប្រជុំសម្រេច
- លេខាធិការអង្គប្រជុំសម្រេចត្រូវស្រង់សេចក្តីសម្រេចបដិសេធចេញពីកំណត់ហេតុប្រជុំសម្រេចចូលក្នុងសម្រង់សេចក្តីសម្រេច (ទ.១២០៣) ចំនួន ៣ច្បាប់ រួចចុះហត្ថលេខា ដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ហើយបោះត្រាឃុំ សង្កាត់ និងចុះកាលបរិច្ឆេទ។ សម្រង់សេចក្តីសម្រេច (ទ.១២០៣) ប្រើប្រាស់ដូចខាងក្រោមៈ

**ទ.១២០៣ ចំនួន ៣ច្បាប់**
- ១ច្បាប់ ជូនអ្នកប្តឹង ឬតំណាង
- ១ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ឧប ពាក់ព័ន្ធ
- ១ច្បាប់ រក្សាទុកជាឯកសារ។

- ជម្រាបអ្នកប្តឹង ឬតំណាងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ កបឃ.ស ទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣)
- ជូនអ្នកប្តឹង ឬតំណាងនូវពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ច្បាប់ (ប្រសិនបើគាត់ស្នើសុំ)។

**២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប**

អ្នកប្តឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ កបឃ.ស មានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ កបឃ.ស។ អ្នកប្តឹង ឬតំណាងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ច្បាប់។

គ.ជ.ប ត្រូវបើកសវនាការសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។

**៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ**

អ្នកប្តឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

ការដាក់ និងការទទួល និងការដោះស្រាយពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

## ៤. គំនូសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត



## VI. របាយការណ៍លទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ និងការវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» ដើម្បីបញ្ជូន និងប្រគល់ជូន លធ.ខប

### ១. ការបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១)

នៅពេលដែលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ ក.ច.ប ត្រូវបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត តាមការិយាល័យបោះឆ្នោត (ទ.១០១១)។

- ប្រសិនបើគ្មានពាក្យបណ្តឹងតវ៉ាអំពីការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ត្រូវបានដាក់នៅ កបឃ.ស ក្នុងរយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទេ ក.ច.ប ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ឱ្យរួចរាល់ នៅមុនពេលវេចខ្ចប់កញ្ចប់ «ក» ដែលនឹងត្រូវអនុវត្តយ៉ាងយូរនៅថ្ងៃទីបួន បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ប្រសិនបើមានពាក្យបណ្តឹងតវ៉ាអំពីការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ត្រូវបានដាក់នៅ កបឃ.ស ក.ច.ប ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ពាក់ព័ន្ធក្នុងឃុំ សង្កាត់ បន្ទាប់ពី កបឃ.ស បានសម្រេចដោះស្រាយពាក្យបណ្តឹងចប់ និងឱ្យបានរួចរាល់នៅមុនពេលវេចខ្ចប់កញ្ចប់ «ក» ដែលអាចនឹងត្រូវអនុវត្តនៅថ្ងៃទីប្រាំពីរ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ក.ច.ប ត្រូវបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ៤ច្បាប់ សម្រាប់ការិយាល័យបោះឆ្នោតនីមួយៗដោយឡែកពីគ្នា ដោយត្រូវផ្អែកតាមរបាយការណ៍នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធដែលមាននៅក្នុងកម្មវិធីកុំព្យូទ័រ។ របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត (ទ.១០១១) ត្រូវប្រើប្រាស់ដូចខាងក្រោម៖

**ទ.១០១១ ចំនួន ៤ច្បាប់**
- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រសម្រាប់ដាក់ក្នុងកញ្ចប់ «ក»
- ២ច្បាប់ កិបភ្ជាប់នៅផ្នែកខាងក្រៅកញ្ចប់ «ក»
- ១ច្បាប់ ក.ច.ប រក្សាទុកជាឯកសាររបស់ ក.ច.ប បន្ទាប់មកទុកជាឯកសារនៅសាលាឃុំ សង្កាត់។

### ២. ការវេចខ្ចប់កញ្ចប់ «ក» តាមការិយាល័យបោះឆ្នោតនីមួយៗ

ក្រោយពីបានបំពេញរបាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ណាមួយរួចភ្លាម ក.ច.ប ត្រូវរៀបចំវេចខ្ចប់រាល់ឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតដាក់ចូលក្នុងកញ្ចប់ «ក» និងត្រូវសរសេរលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ និងការិយាល័យបោះឆ្នោត សម្គាល់ពីខាងក្រៅកញ្ចប់ «ក» នោះ។

**ឯកសារដែលត្រូវដាក់ក្នុងកញ្ចប់ «ក» មាន៖**

- ស្រោមសំបុត្រដាក់រាល់សម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ កបឃ.ស យល់ព្រមលើពាក្យបណ្តឹងតវ៉ា ដែលតម្រូវឱ្យ ក.ច.ប ចុះឈ្មោះអ្នកប្តឹងតវ៉ាសុំចុះឈ្មោះបោះឆ្នោតទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ (ប្រសិនបើមាន)
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ១ច្បាប់។




ប្រធាន ក.ច.ប ត្រូវធានាថា៖

- បានដាក់ឯកសារត្រឹមត្រូវហើយ មុននឹងចង ឬបិទភ្ជិតកញ្ចប់ «ក»
- បានវេចខ្ចប់ និងចងមាត់កញ្ចប់ «ក» ចំពោះមុខសមាជិក កបឃ.ស ប្រចាំការ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតដែលមានវត្តមាន
- បានសរសេរលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ ការិយាល័យបោះឆ្នោត នៅលើកញ្ចប់ «ក» (ប៊ិកហ្សឺតលុបមិនជ្រះ)
- របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ២ច្បាប់ ត្រូវកិបភ្ជាប់ទៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ «ក»
- ថែរក្សាឱ្យបានល្អមុនវេចខ្ចប់ចូលស្បោង «ខ»។

### ៣. ការបំពេញរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២)

ប្រសិនបើគ្មានពាក្យបណ្ដឹងតវ៉ា ត្រូវបានដាក់នៅ គបឃ.ស ក្នុងរយៈពេល ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទេ ក.ច.ប ត្រូវធ្វើរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ឱ្យរួចរាល់នៅមុនពេលវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ»។

ប្រសិនបើមានពាក្យបណ្ដឹងតវ៉ាអំពីការបដិសេធការសុំចុះឈ្មោះបោះឆ្នោត ត្រូវបានដាក់ពាក្យបណ្ដឹងនៅ គបឃ.ស ក.ច.ប ត្រូវធ្វើរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) បន្ទាប់ពី គបឃ.ស បានសម្រេចដោះស្រាយពាក្យបណ្ដឹងចប់ និងឱ្យបានរួចរាល់នៅមុនពេលវេចខ្ចប់កញ្ចប់ «ក» ដាក់ក្នុងស្បោង «ខ» ។

ក.ច.ប ត្រូវបំពេញរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ចំនួន ៣ច្បាប់ ដោយផ្អែកលើរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) គួលេខមួយចំនួនទៀតដែលទាក់ទងនឹងចំនួនការិយាល័យបោះឆ្នោត និងចំនួន ទ.១០២២ ព្រមទាំងផ្អែកតាមរបាយការណ៍ ទ.១០១២ ដែលមាននៅក្នុងកម្មវិធីកុំព្យូទ័រ។ ទ.១០១២ ត្រូវប្រើប្រាស់ដូចខាងក្រោម៖

**ទ.១០១២ ចំនួន ៣ច្បាប់**
- ២ច្បាប់ ច្រកទៅក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង «ខ» នីមួយៗ (ផ្ញើជូន គ.ជ.ប ១ច្បាប់ និងផ្ញើជូន លធ.ខប ១ច្បាប់)
- ១ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ ដែលបន្ទាប់មករក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់។

នៅក្រោយពេលបានបំពេញរបាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) រួចភ្លាម ក.ច.ប ត្រូវរៀបចំវេចខ្ចប់កញ្ចប់ «ក» ឬ/និងរាល់សម្ភារ ឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតទាំងអស់ ដាក់ទៅក្នុងស្បោង «ខ» តាមចំនួនដែលអាចដាក់បាន និងបំពេញលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារ និងការបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ៤ច្បាប់ សម្រាប់ប្រើប្រាស់ដូចខាងក្រោម៖

**ទ.១០១៣ ចំនួន ៤ច្បាប់**
- ២ច្បាប់ ច្រកទៅក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង «ខ»
- ១ច្បាប់ ដាក់ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ»
- ១ច្បាប់ ទុកសម្រាប់ពេលប្រគល់ ទទួលនៅ លធ.ខប (ដែលបន្ទាប់មករក្សានៅសាលាឃុំ សង្កាត់)។

៨. ការបំពេញរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១)

ក.ច.ប ត្រូវបន្តបំពេញរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ចំនួន ៤ច្បាប់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ឱ្យប្រាកដថាគល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានទទួលស្មើនឹង ទ.១០២២ ដែលបានប្រើ បូកនឹង ទ.១០២២ ដែលនៅសល់មិនទាន់ប្រើ។ ទ.១០២១ ត្រូវប្រើប្រាស់ដូចខាងក្រោម ៖

**ទ.១០២១ ចំនួន ៤ច្បាប់**

- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្រ រួចដាក់ក្នុងកញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយ
- ១ច្បាប់ កិបភ្ជាប់ផ្នែកខាងក្រៅនៃកញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយ
- ១ច្បាប់ ច្រកក្នុងស្រោមសំបុត្ររួចដាក់ក្នុងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ
- ១ច្បាប់ ក.ច.ប រក្សាទុកជាឯកសារ ដែលបន្ទាប់មករក្សាទុកជាឯកសារនៅសាលាឃុំ សង្កាត់។

៩. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយ និងទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់

ក.ច.ប ត្រូវធានាថា រាល់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានប្រើហើយ និងទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ (ទ.១០២២ មានអត្តលេខ និង ទ.១០២២ គ្មានអត្តលេខ) ត្រូវដាក់ទៅក្នុងកញ្ចប់ដោយឡែកពីគ្នា ដែលត្រៀមបម្រុងស្រាប់ ដោយដាក់ភ្ជាប់ជាមួយនូវរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ។

ក. ការវេចខ្ចប់កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់

ឯកសារដែលត្រូវដាក់ក្នុងកញ្ចប់នេះមាន៖

- រាល់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយ គិតទាំងខូច និងនៅសល់ក្នុងដុំដែលបានប្រើហើយ សរុបក្នុងឃុំសង្កាត់

- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ចំនួន ១ច្បាប់។

**កញ្ចប់ដាក់គល់សន្លឹកបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ**
**ប្រើហើយ (ទ.១០២២ មានអត្តលេខ និងគ្មានអត្តលេខ)**

**រាជធានី ខេត្ត** **ឃុំ សង្កាត់**

- រាល់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយ សរុបក្នុងឃុំ សង្កាត់ គិតទាំងខូច និងនៅសល់ក្នុងដុំដែលបានប្រើហើយ សរុបក្នុងឃុំ សង្កាត់
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ចំនួន ១ច្បាប់។

ទ.១០២១ ចំនួន ១ច្បាប់

បន្ទាប់ពីវេចខ្ចប់កញ្ចប់នោះរួច គ.ច.ប ត្រូវ៖

- កិបភ្ជាប់របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ចំនួន ១ច្បាប់ នៅផ្នែកខាងក្រៅនៃកញ្ចប់
- រក្សាទុកជាឯកសារនូវរបាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ចំនួន ១ច្បាប់
- សរសេរសម្គាល់លេខកូដរាជធានី ខេត្ត លេខកូដឃុំ សង្កាត់នៅលើកញ្ចប់ឱ្យបានត្រឹមត្រូវច្បាស់លាស់។

**ខ. ការវេចខ្ចប់កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើ**

ក.ច.ប ត្រូវវេចខ្ចប់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដែលនៅសល់មិនទាន់ប្រើ ព្រមទាំងដាក់ទៅក្នុងកញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះដែលនៅសល់មិនទាន់ប្រើ។ ឯកសារដែលត្រូវដាក់ក្នុងកញ្ចប់នេះមាន៖

- ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ និង ទ.១០២២ គ្មានអត្តលេខ) ដែលនៅសល់មិនទាន់ប្រើ
- ស្រោមសំបុត្រដាក់របាយការណ៍ស្តីពីតុល្យភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ចំនួន ១ច្បាប់
- សរសេរសម្គាល់លេខកូដរាជធានី ខេត្ត និងលេខកូដឃុំ សង្កាត់នៅលើផ្នែកខាងក្រៅនៃកញ្ចប់នេះ។

| |
|---|
| **កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ដែលនៅសល់មិនទាន់ប្រើ**<br>☐☐ ☐☐☐<br>**រាជធានី ខេត្ត** **ឃុំ សង្កាត់**<br>- ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ និង ទ.១០២២ គ្មានអត្តលេខ) ដែលនៅសល់មិនទាន់ប្រើ<br>- ស្រោមសំបុត្រដាកកញ្ចប់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២១) ចំនួន ១ច្បាប់។ |

បញ្ជាក់៖

- ☛ បន្ទាប់ពីវេចខ្ចប់កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើនោះរួច ក.ច.ប ត្រូវដាក់កញ្ចប់នោះ ទៅក្នុងកេសស័ង្កសី ហើយសរសេរលេខកូដរាជធានី ខេត្ត លេខកូដឃុំ សង្កាត់នៅលើកេសស័ង្កសីឱ្យបានត្រឹមត្រូវច្បាស់លាស់។
- ☛ កេសស័ង្កសីដែលដាក់កញ្ចប់ដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោតដែលនៅសល់មិនទាន់ប្រើ ត្រូវប្រគល់ជូន លធ.ខប និងរក្សាទុកនៅ លធ.ខប ស្របពេលនឹងការបញ្ជូន និងការប្រគល់ស្បោង «ខ»។

### ៦. ការវេចខ្ចប់សម្ភារ ឯកសារដាក់ក្នុងស្បោង «ខ» បញ្ជូនទៅ លធ.ខប

ក.ច.ប ត្រូវចាត់ចែងវេចខ្ចប់កញ្ចប់ «ក» និងសម្ភារ ឯកសារពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោតទាំងអស់ ដោយដាក់ទៅក្នុងស្បោង «ខ» តាមចំនួនដែលអាចដាក់អស់កញ្ចប់ «ក» និងសម្ភារ ឯកសារទាំងនោះ ដើម្បីបញ្ជូនទៅ លធ.ខប។

#### ក. ការវេចខ្ចប់ស្បោង «ខ» ទី១

សម្ភារ ឯកសារដែលត្រូវដាក់ក្នុងស្បោង «ខ» ទី១ មាន៖

- កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២ មានអត្តលេខ និង ទ.១០២២ គ្មានអត្តលេខ) ដែលបានប្រើហើយ
- ស្រោមសំបុត្រដាក់របាយការណ៍សរុបស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ចំនួន ២ (ពីរ) ច្បាប់
- ស្រោមសំបុត្រដាក់គល់បង្កាន់ដៃប្ដូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨)

- ស្រោមសំបុត្រដាក់រាល់សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១០០៩)
- ស្រោមសំបុត្រដាក់រាល់ពាក្យបណ្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោត (ទ.១២០២) ដែលត្រូវបានដាក់ប្តឹងនៅក្រោយពេលកំណត់
- ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ២ច្បាប់។



ចំណាំ៖

- ករណីស្បោង «ខ» ទី១ មានចំនួនសរុបលើសពីមួយ ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោង «ខ» ទី១ ទាំងនោះនូវលេខនៃស្បោងនីមួយៗ។ ឧទាហរណ៍ ស្បោង «ខ» ទី១ សរុបមានចំនួន ២ ត្រូវសរសេរសម្គាល់នូវលេខរៀងថា ១/២ ឬ២/២។

**ខ. ការវេចខ្ចប់ស្បោង «ខ» ទី២ និងស្បោង «ខ» បន្តបន្ទាប់**

ក.ច.ប ត្រូវរៀបចំវេចខ្ចប់ស្បោង«ខ»ទី២និងស្បោង«ខ»បន្តបន្ទាប់ តាមចំនួនចាំបាច់ ដែលត្រូវរៀបចំដាក់កញ្ចប់ «ក» នៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់។ សម្ភារ ឯកសារដែលត្រូវដាក់ក្នុងស្បោង «ខ» ទី២ និងស្បោង «ខ» បន្តបន្ទាប់រួមមាន៖

- កញ្ចប់ «ក» តាមចំនួនដែលអាចដាក់បានក្នុងស្បោង «ខ»ទី២ នីមួយៗ។ កញ្ចប់ «ក» ដែលត្រូវដាក់ក្នុងស្បោង «ខ»ទី២ តែមួយ ត្រូវតែបានរៀបចំតាមលេខកូដការិយាល័យបោះឆ្នោតជាប់គ្នា និងតាមលំដាប់លំដោយ
- ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ២ (ពីរ) ច្បាប់។



ចំណាំ៖

- ☛ ករណីស្បោង «ខ» ទី២ និងស្បោង «ខ» បន្តបន្ទាប់ មានចំនួនសរុបលើសពីមួយ ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោង «ខ» ទី២ និងស្បោង «ខ» បន្តបន្ទាប់ទាំងនោះនូវលេខនៃស្បោងនីមួយៗ។ ឧទាហរណ៍ ស្បោង «ខ» ទី២ និងស្បោង «ខ» បន្តបន្ទាប់ សរុបមានចំនួន៣ ត្រូវសរសេរសម្គាល់នូវលេខរៀងថា ១/៣ ២/៣ ៣/៣។
- ☛ មុននឹងចងមាត់ស្បោង «ខ» ក.ច.ប ត្រូវធានាថា គ្មាននៅសល់សម្ភារ ឯកសារណាមួយដែលមិនទាន់បានដាក់ក្នុងស្បោង «ខ» នីមួយៗនោះឡើយ។ ស្បោង «ខ» ដែលចងមាត់រួច អាចនឹងបើកឡើងវិញបានតែក្នុងពេលបំពេញភារកិច្ចត្រួតពិនិត្យការទទួលសម្ភារ ឯកសារនៅ លធ.ខប និងនៅ ន.គ.ទ.ប ប៉ុណ្ណោះ។ ក.ច.ប ត្រូវធានាថា៖
  - លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ១ (មួយ) ច្បាប់ក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ»
  - ពេលចងមាត់ស្បោង «ខ»រួច ត្រូវសរសេរសម្គាល់លេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ឱ្យបានត្រឹមត្រូវ ដោយប៊ិកហ្វឺតលុបមិនជ្រះ នៅត្រង់ចន្លោះទំនេរផ្នែកខាងលើហោប៉ៅខាងក្រៅនៃស្បោង «ខ»
  - ការពារ និងថែរក្សាសុវត្ថិភាពស្បោង «ខ» ឱ្យបានល្អ នៅមុនពេល និងក្នុងពេលបញ្ជូនទៅ លធ.ខប។

## ៧. ការបញ្ជូនស្បោង «ខ» ទៅ លធ.ខប

- ក.ច.ប ត្រូវទទួលបន្ទុកការបញ្ជូន និងការប្រគល់ស្បោង «ខ» ដោយផ្ទាល់នៅ លធ.ខប
- លធ.ខប អាចចាត់មន្ត្រីរបស់ខ្លួនឱ្យចុះត្រួតពិនិត្យ និងទទួលយកស្បោង «ខ» នៅតាមឃុំ សង្កាត់ក៏បាន
- មន្ត្រីទទួលបន្ទុកទទួលសម្ភារ ឯកសារនៃ លធ.ខប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ទាំង ៤ (បួន) ច្បាប់ រួចប្រគល់ឱ្យ ក.ច.ប ១ (មួយ) ច្បាប់វិញ ទុកជាឯកសារនៅសាលាឃុំ សង្កាត់
- ភ្នាក់ងារគណបក្សនយោបាយប្រចាំឃុំ សង្កាត់នីមួយៗ និងអ្នកសង្កេតការណ៍បោះឆ្នោត អាចរួមដំណើរសង្កេតមើល និងអាចធ្វើជាសាក្សីក្នុងការប្រគល់ទទួលស្បោង «ខ» និងសម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត។

## ៨. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប និងការវេចខ្ចប់ស្បោង «ខ» ដាក់ក្នុងស្បោង «គ» បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត

នៅពេលប្រគល់ ទទួលស្បោង «ខ» ពី ក.ច.ប មន្ត្រី លធ.ខប ត្រូវត្រួតពិនិត្យថា ស្បោង «ខ» ទាំងឡាយមិនត្រូវបានគេរុះរើឡើយ។ នៅចំពោះមុខ ក.ច.ប នៃឃុំ សង្កាត់ពាក់ព័ន្ធ មន្ត្រី លធ.ខប ត្រូវត្រួតពិនិត្យឱ្យប្រាកដថា ស្បោង «ខ» នីមួយៗមានផ្ទុកកញ្ចប់ «ក» ឬ/និងកញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយសរុប ក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតគ្រប់ចំនួន។

### ក. ការត្រួតពិនិត្យស្បោង «ខ» នៅ លធ.ខប

➢ **ករណីស្បោង «ខ» មិនមានការរុះរើ**

ក្នុងការត្រួតពិនិត្យ ប្រសិនបើមន្ត្រី លធ.ខប រកមិនឃើញមានស្បោង «ខ» ណាមួយត្រូវបានគេរុះរើទេ ត្រូវបន្តការត្រួតពិនិត្យ ដោយការបើកស្បោង «ខ» ម្តងមួយៗ ដើម្បីផ្ទៀងផ្ទាត់ចំនួនកញ្ចប់ «ក» កញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ទម្រង់ផ្សេងទៀតដែលមានក្នុងស្បោង «ខ» នោះ។

មន្ត្រី លធ.ខប ត្រូវបើកស្បោង «ខ» ម្តងមួយៗរហូតដល់អស់ស្បោង «ខ» នៃឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីផ្ទៀងផ្ទាត់កញ្ចប់ «ក» និងកញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀត ដែលមាននៅខាងក្នុងយ៉ាងហ្មត់ចត់ ដោយផ្អែកលើលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ដែលដាក់ក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ»។ ប្រសិនបើកញ្ចប់ «ក» និងកញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយ សរុបក្នុងឃុំ សង្កាត់ណាមួយ មិនត្រូវបានរុះរើទេ មន្ត្រី លធ.ខប ត្រូវ៖

- គ្រាន់តែពិនិត្យ និងរាប់ចំនួនកញ្ចប់ «ក» និងកញ្ចប់ដាក់គល់សន្លឹក ទ.១០២២ ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ ឬ/និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតប៉ុណ្ណោះ ដោយមិនចាំបាច់បើកកញ្ចប់ «ក» ឬកញ្ចប់សម្ភារឯកសារចុះឈ្មោះបោះឆ្នោតទាំងនោះ ដើម្បីធ្វើការផ្ទៀងផ្ទាត់ឡើងវិញទេ

- ដកយករបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ១ច្បាប់ ក្នុងចំណោម ២ច្បាប់ ដែលកិបភ្ជាប់នៅនឹងផ្នែកខាងក្រៅនៃកញ្ចប់ «ក» ដើម្បីប្រើសម្រាប់ផ្ទៀងផ្ទាត់ និងរក្សាទុកជាឯកសារ
- ដកយកលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ដែលមានក្នុងស្រោមសំបុត្រក្នុងស្បោង «ខ» ចំនួន ២ (ពីរ) ច្បាប់ ក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ» ចំនួន ១ (មួយ) ច្បាប់ និងយក ១ (មួយ) ច្បាប់ទៀតពី ក.ច.ប រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា លធ.ខប ហើយប្រគល់ ១ (មួយ) ច្បាប់ជូន ក.ច.ប វិញ ដើម្បីបញ្ជាក់ថាបានទទួល
- រៀបចំដាក់កញ្ចប់ «ក» ឬ/និងកញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ និងស្រោមសំបុត្រដាក់ទម្រង់បែបបទផ្សេងទៀតទៅក្នុងស្បោង «ខ» ដដែលវិញ រួចច្រកលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) ចំនួន ១ (មួយ) ច្បាប់ក្នុងស្រោមសំបុត្រដាក់ទៅក្នុងស្បោង «ខ» និងដាក់ ១ (មួយ) ច្បាប់ទៀតទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង «ខ»
- ចងភ្ជិតមាត់ស្បោង «ខ» រួចរក្សាទុកនៅកន្លែងមានសុវត្ថិភាព សម្រាប់ត្រៀមវេចខ្ចប់ដាក់ក្នុងស្បោង «គ» ដើម្បីបញ្ជូនមក គ.ជ.ប។

➢ **ករណីស្បោង «ខ» មានការរុះរើ**

ក្នុងការត្រួតពិនិត្យ ប្រសិនបើមន្ត្រី លធ.ខប រកឃើញថា មានស្បោង «ខ» ណាមួយត្រូវបានគេរុះរើ ក.ច.ប ដែលបានបញ្ជូន និងប្រគល់ស្បោង «ខ» ពាក់ព័ន្ធនឹងត្រូវបានស្នើឱ្យបំភ្លឺករណីនេះ។

ប្រសិនបើក្នុងការត្រួតពិនិត្យខាងលើមានភស្តុតាងបញ្ជាក់ថា មានកញ្ចប់ «ក» ណាមួយ ឬកញ្ចប់ដាក់គល់សន្លឹកទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលបានប្រើហើយសរុបក្នុងឃុំ សង្កាត់ នៅក្នុងស្បោង «ខ» ត្រូវបានគេរុះរើ មន្ត្រី លធ.ខប ត្រូវ៖

- បើកកញ្ចប់ «ក» ដែលមានការរុះរើនោះ និងផ្ទៀងផ្ទាត់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតនៅខាងក្នុងយ៉ាងហ្មត់ចត់ទៅជាមួយនឹងរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យ

បោះឆ្នោត (ទ.១០១១) ដែលមាននៅខាងក្នុងកញ្ចប់«ក» និង មានកិបភ្ជាប់នៅផ្នែកខាងក្រៅនៃកញ្ចប់ «ក»

- ដកយករបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ចំនួន ១ (មួយ) ច្បាប់ ក្នុងចំណោម ២ (ពីរ) ច្បាប់ដែលមានកិបភ្ជាប់នៅផ្នែកខាងក្រៅនៃកញ្ចប់ «ក» ដើម្បីប្រើ និងរក្សាទុកជាឯកសារ
- ឱ្យ ក.ច.ប ដែលបានបញ្ជូន និងប្រគល់ស្បោង «ខ» ធ្វើការបំភ្លឺក្នុងករណីដែលបានរកឃើញថា មានភាពមិនត្រឹមត្រូវ
- ចាត់តាំងក្រុមស្រាវជ្រាវមួយដែលមានសមាសភាព ២រូប ជាបន្ទាន់ ដើម្បីសហការជាមួយ ក.ច.ប ពាក់ព័ន្ធក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវរាល់សម្ភារ ឯកសារដែលមានក្នុងកញ្ចប់ «ក» ជាមួយរបាយការណ៍ស្ដីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និងឯកសារពាក់ព័ន្ធផ្សេងទៀត
- ធ្វើរបាយការណ៍លម្អិតអំពីភស្តុតាងនៃអំពើល្មើស និងលទ្ធផលនៃការរកឃើញជូន គ.ជ.ប ជាបន្ទាន់ ក្នុងករណីដែលក្រុមស្រាវជ្រាវនៃ លធ.ខប បានរកឃើញថា មានការក្លែងបន្លំក្នុងការចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះ
- វេចខ្ចប់កញ្ចប់ «ក» ដែលមានបញ្ហាឡើងវិញរួចបន្តពិនិត្យកញ្ចប់ «ក» ដទៃទៀត
- ត្រូវសរសេរបន្ថែមនូវមូលវិចារអំពីកញ្ចប់ «ក» ដែលត្រូវរុះរើ និងកត់ត្រាលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធលើលិខិតបញ្ជាក់ការវេចខ្ចប់សម្ភារឯកសារចុះឈ្មោះបោះឆ្នោត និងបញ្ជូនស្បោង «ខ» ដោយក្រុមចុះឈ្មោះបោះឆ្នោត (ទ.១០១៣) គ្រប់ច្បាប់។

**ចំណាំ៖**

- គ.ជ.ប ត្រូវមានវិធានការតាមច្បាប់ ចំពោះជនប្រព្រឹត្តអំពើល្មើស ដោយផ្អែកលើរបាយការណ៍ និងភស្តុតាងដែលមន្ត្រី លធ.ខប បានបញ្ជូនមក។
- មន្ត្រី លធ.ខប ត្រូវរៀបចំគម្រោងផែនការទទួល ត្រួតពិនិត្យ វេចខ្ចប់ និងបញ្ជូនសម្ភារឯកសារនៃការចុះឈ្មោះបោះឆ្នោតទៅ គ.ជ.ប ដែលអាចនឹងត្រូវអនុវត្តនៅចន្លោះរយៈពេល ៩ថ្ងៃ ទៅ ១២ថ្ងៃ ក្រោយថ្ងៃបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់។

- នៅពេលបានទទួល ត្រួតពិនិត្យ និងវេចខ្ចប់ស្បោង «ខ» ឡើងវិញរួចហើយ មន្ត្រី លធ.ឧប ត្រូវចាត់ចែងវេចខ្ចប់ស្បោង «ខ» ដោយដាក់ក្នុងស្បោង «គ» សម្រាប់បញ្ជូន និងប្រគល់ទៅ ន.គ.ទ.ប ឱ្យឆាប់បំផុតតាមដែលអាចធ្វើបាន។
- កេសស័ង្កសី ដែលដាក់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ដែលនៅសល់មិនទាន់ប្រើសរុបក្នុងឃុំ សង្កាត់ ត្រូវប្រគល់ឱ្យ លធ.ឧប និងរក្សាទុកនៅ លធ.ឧប ស្របពេលនឹងការបញ្ជូន និងការប្រគល់ស្បោង «ខ»។

**ខ. ការវេចខ្ចប់ស្បោង «គ» បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត**

នៅមួយថ្ងៃ មុនថ្ងៃបញ្ជូន និងប្រគល់ស្បោង «គ» ទៅ ន.គ.ទ.ប មន្ត្រី លធ.ឧប ត្រូវ៖

- ច្រកស្បោង «ខ» ទាំងអស់ដែលបានចងមាត់រួចហើយ បញ្ចូលទៅក្នុងស្បោង «គ» តាមចំនួនដែលត្រូវការចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង «ខ»
- បំពេញលិខិតបញ្ជាក់ការវេចខ្ចប់ស្បោង «ខ» និងការបញ្ជូនស្បោង «គ» ដោយ លធ.ឧប (ទ.១០១៤) ចំនួន ៣ (បី) ច្បាប់ ដោយចុះហត្ថលេខា ឈ្មោះ កាលបរិច្ឆេទ និងបោះត្រា លធ.ឧប ឱ្យបានត្រឹមត្រូវ។ លិខិតបញ្ជាក់ការវេចខ្ចប់ស្បោង «ខ» និងការបញ្ជូនស្បោង «គ» ដោយ លធ.ឧប (ទ.១០១៤) ត្រូវប្រើប្រាស់ដូចខាងក្រោម៖

**ទ.១០១៤ ចំនួន ៣ច្បាប់**
- ១ច្បាប់ ច្រកទៅក្នុងស្រោមសំបុត្រ រួចដាក់ក្នុងស្បោង «គ»
- ១ច្បាប់ ដាក់ហោប៉ៅខាងក្រៅនៃស្បោង«គ»
- ១ច្បាប់ ទុកឱ្យមន្ត្រី លធ.ឧប ប្រើពេលប្រគល់ទទួលនៅ គ.ជ.ប។

- ដាក់រាល់ស្រោមសំបុត្រដែលមានលិខិតបញ្ជាក់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតដែលត្រូវបានផ្គត់ផ្គង់បន្ថែម (ទ.១០១៥) ដែលត្រូវផ្ញើជូន ន.ប្រតិបត្តិការ
- រូតខ្សែចងមាត់ស្បោង «គ» រួចត្រូវបំពេញលេខកូដរាជធានី ខេត្ត នៅក្នុងប្រឡោះដែលបោះពុម្ពស្រាប់ នៅផ្នែកខាងលើហោប៉ៅខាងក្រៅនៃស្បោង «គ» នីមួយៗ។

➢ **សម្ភារ ឯកសារដែលត្រូវដាក់ក្នុងស្បោង «គ» រួមមាន៖**

- ស្បោង «ខ» តាមចំនួនដែលអាចដាក់បាន
- ស្រោមសំបុត្រដាក់លិខិតបញ្ជាក់ការវេចខ្ចប់ស្បោង «ខ» និងការបញ្ជូនស្បោង «គ» ដោយ លធ.ឧប (ទ.១០១៤) ចំនួន ១ (មួយ) ច្បាប់
- រាល់ស្រោមសំបុត្រដាក់លិខិតបញ្ជាក់សម្ភារ ឯកសារចុះឈ្មោះបោះឆ្នោតដែលត្រូវបានផ្គត់ផ្គង់បន្ថែម (ទ.១០១៥) ដែលត្រូវផ្ញើជូន ន.ប្រតិបត្តិការ។




ពេលចងមាត់ស្បោង «គ» រួច លធ.ឌប ត្រូវ៖

- សរសេរលេខកូដរាជធានី ខេត្ត
- ដាក់លិខិតបញ្ជាក់ការវេចខ្ចប់ស្បោង «ខ» និងការបញ្ជូនស្បោង «គ» ដោយ លធ.ឌប (ទ.១០១៤) ចំនួន ១ (មួយ) ច្បាប់ក្នុងហោប៉ៅខាងក្រៅនៃស្បោង «គ»។

➢ **ការប្រគល់ ទទួលស្បោង «គ» នៅ គ.ជ.ប**

នៅរាល់ពេលនៃការប្រគល់ ទទួលស្បោង «គ» នៅ គ.ជ.ប មន្ត្រីទទួលបន្ទុកការបញ្ជូននៃ លធ.ឌប ត្រូវធានាថា មន្ត្រីទទួលសម្ភារ ឯកសារនៅ ន.គ.ទ.ប បានចុះហត្ថលេខាលើ ទ.១០១៤ ទាំង ៣ (បី) ច្បាប់ រួចប្រគល់ជូនមន្ត្រីទទួលបន្ទុកការបញ្ជូននៃ លធ.ឌប វិញចំនួន ១ច្បាប់ ដើម្បីបញ្ជាក់ថា បានទទួលគ្រប់ចំនួន។ ន.គ.ទ.ប ត្រូវត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ និងឯកសារសម្រាប់ការចុះឈ្មោះបោះឆ្នោត ដែលមន្ត្រី លធ.ឌប បានបញ្ជូនមក និងរបាយការណ៍ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត (ទ.១០១១) និងរបាយការណ៍សរុបស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១០១២) ដែលជូនភ្ជាប់មកជាមួយក្នុងស្បោង «គ» ជាមួយចំនួនសរុបទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យនៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ។

៩. ការវេចខ្ចប់សម្ភារ ឯកសារផ្សេងៗទៀត ដែលបានផ្គត់ផ្គង់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតបញ្ជូនទៅ គ.ជ.ប

រាល់សម្ភារ បរិក្ខារបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ដែលនៅសល់ក្រៅពីការវេចខ្ចប់ដាក់ក្នុងស្បោង «គ» មន្ត្រីលធ.ឧបត្រូវធ្វើការពិនិត្យប្រមូលវេចខ្ចប់នូវរាល់សម្ភារ បរិក្ខារ និងឯកសារបម្រើឱ្យការចុះឈ្មោះបោះឆ្នោតផ្សេងទៀតដែលតម្រូវឱ្យប្រគល់មក គ.ជ.ប វិញទន្ទឹមនឹងការបញ្ជូន និងការប្រគល់ ស្បោង «គ» នៅ ន.គ.ទ.ប។ សម្ភារ បរិក្ខារនៅសល់ ត្រូវប្រគល់ ទទួលនៅឃ្លាំងរបស់ គ.ជ.ប។

## VII. ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតជាសាធារណៈសម្រាប់គោលដៅនៃការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់

បន្ទាប់ពីបានពិនិត្យផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតក្នុងប្រព័ន្ធផ្ទុកទិន្នន័យរួចរាល់ គ.ជ.ប ត្រូវធ្វើការបោះពុម្ព និងចាត់ឱ្យ កបឃ.ស បិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតដំបូង រួមនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗនៅតាមសាលាឃុំ សង្កាត់ និងទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់តាមការកំណត់របស់ គ.ជ.ប ក្នុងគោលដៅនៃការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូង ព្រមទាំងផ្ដល់ជូន កបឃ.ស ១ (មួយ) ច្បាប់ សម្រាប់ប្រើប្រាស់តាមការចាំបាច់។

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតដំបូងជាច្បាប់ចតចម្លងបានដោយបង់ថ្លៃ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ។

### ១. ទីកន្លែងផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង

- បិទផ្សាយចំនួន ១ (មួយ) ច្បាប់ រួមនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ នៅសាលាឃុំ សង្កាត់
- បិទផ្សាយចំនួន ១ (មួយ) ច្បាប់ រួមនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ នៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់

កបឃ.ស ត្រូវធ្វើកំណត់ហេតុនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងចំនួន ៤ (បួន) ច្បាប់ ដោយបញ្ជាក់អំពីពេលវេលា កាលបរិច្ឆេទ ទីកន្លែងបិទផ្សាយ ចុះហត្ថលេខា និង បោះត្រាឃុំ សង្កាត់ រួចត្រូវៈ

- បិទភ្ជាប់នឹងបញ្ជីបោះឆ្នោតដំបូង ដែលត្រូវបិទផ្សាយនៅសាលាឃុំ សង្កាត់ចំនួន ១ (មួយ) ច្បាប់
- បិទភ្ជាប់នឹងបញ្ជីបោះឆ្នោតដំបូង ដែលត្រូវបិទផ្សាយនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់ចំនួន ១ (មួយ) ច្បាប់
- ទុកជាឯកសារនៅសាលាឃុំ សង្កាត់ចំនួន ១ (មួយ) ច្បាប់

- ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប ពាក់ព័ន្ធ ចំនួន ១ (មួយ) ច្បាប់។

**ចំណាំ៖**

- លធ.ខប ត្រូវធ្វើរបាយការណ៍អំពីកាលបរិច្ឆេទ និងទីកន្លែងនៃការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប ដោយផ្អែកលើកំណត់ហេតុរបស់ កបឃ.ស។

**២. កាលបរិច្ឆេទនៃការផ្សព្វផ្សាយបញ្ជីបោះឆ្នោតដំបូង**

ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ទូទាំងប្រទេសត្រូវធ្វើនៅ**ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៧**។

ក្នុងរយៈពេលបិទផ្សាយ កបឃ.ស ស្មៀនឃុំ សង្កាត់ និងមេភូមិត្រូវផ្សព្វផ្សាយបំផុសលើកទឹកចិត្តប្រជាពលរដ្ឋ ដែលជាអ្នកបោះឆ្នោតគ្រប់រូបឱ្យទៅមើលឈ្មោះ និងពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យពាក់ព័ន្ធរបស់ខ្លួនតាមទីតាំងដែលបានបិទផ្សាយ ឬតាមអាសយដ្ឋានវេប voterlist.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH ។

ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ក្នុងករណីគ្មានពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ណាមួយទេនោះ កបឃ.ស ត្រូវធ្វើរបាយការណ៍ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប។

## VIII. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង

ជនណាក៏ដោយមានសិទ្ធិប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរតាមពាក្យបណ្ដឹង (ទ.១២០២) ទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតទៅ កបឃ.ស ក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។

| | |
|---|---|
| *ពាក្យបណ្ដឹងតវ៉ា អាចធ្វើឡើងអំពីការបាត់ឈ្មោះរបស់អ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់ ឬត្រូវបាន គ.ជ.ប លុបឈ្មោះមិនត្រឹមត្រូវតាមករណីដូចខាងក្រោម៖*<br>-មិនឃើញមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង (មានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ឬបង្កាន់ដៃបញ្ជាក់ការប្ដូរការិយាល័យក្នុងឃុំ សង្កាត់ជាភស្តុតាង)<br>-មានឈ្មោះ ប៉ុន្តែឈ្មោះនោះស្ថិតនៅក្នុងការិយាល័យផ្សេងទៅវិញ<br>-មានឈ្មោះ ប៉ុន្តែឈ្មោះរបស់គាត់ ឬ/និងទិន្នន័យរបស់គាត់មានភាពមិនត្រឹមត្រូវតាមព័ត៌មានដែលគាត់បានផ្ដល់ឱ្យ<br>-ឃើញឈ្មោះដែរ តែឈ្មោះនោះស្ថិតនៅក្នុងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់។ | *ពាក្យបណ្ដឹងជំទាស់ អាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង៖*<br>-មានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង តែជននោះមិនមានលក្ខខណ្ឌគ្រប់គ្រាន់ ៖<br>०មិនមានសញ្ជាតិខ្មែរ។<br>०មិនទាន់គ្រប់អាយុចុះឈ្មោះបោះឆ្នោតស្របតាមច្បាប់។<br>०មិនមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់នោះ។<br>०ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច។<br>- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាង ១កន្លែង។ |

<table>
<tr><td colspan="2">១. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងតវ៉ា ឬ/និងពាក្យបណ្ដឹងជំទាស់នៅ កបឃ.ស</td></tr>
<tr><td colspan="2">ក. ការប្ដឹងតវ៉ា ឬ/និងការប្ដឹងជំទាស់</td></tr>
<tr><td>ការប្ដឹងតវ៉ា</td><td>ការប្ដឹងជំទាស់</td></tr>
<tr><td>ការប្ដឹងតវ៉ាត្រូវធ្វើក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។</td><td>ការប្ដឹងជំទាស់ត្រូវធ្វើក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។</td></tr>
<tr><td colspan="2">ខ. ការទទួលពាក្យបណ្ដឹង</td></tr>
<tr><td>ពាក្យបណ្ដឹងតវ៉ា<br>- នៅពេលទទួលពាក្យបណ្ដឹង កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន មានជាអាទិ៍៖<br>○ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬ/និងតំណាង<br>○ កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពអំឡុងពេលកំណត់ ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។<br>- ត្រូវធ្វើកំណត់ហេតុសាកសួរអ្នកប្ដឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃលើកំណត់ហេតុនោះ។ ក្នុងករណីអ្នកប្ដឹងមិនព្រមផ្ដិតមេដៃ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃ លើកំណត់ហេតុនេះ<br>- ទ.១២០២ ចំនួន ៣ច្បាប់ ចុះកាលបរិច្ឆេទ ពេលវេលាទទួល កាលបរិច្ឆេទ ពេលវេលាប្រជុំសម្រេច<br>ទ.១២០២=៣ច្បាប់<br>- ១ច្បាប់ ជូនអ្នកប្ដឹងតវ៉ា ឬ តំណាង<br>- ១ច្បាប់ បិទផ្សាយនៅសាលា ឃុំសង្កាត់<br>- ១ច្បាប់ រក្សាទុកប្រើប្រាស់ក្នុងការប្រជុំសម្រេច<br>- ពាក្យបណ្ដឹងដែលគោរពអំឡុងពេលកំណត់ កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន និងដោយ សំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង<br>- អ្នកប្ដឹងបង្ហាញឯកសារភស្ដុតាង ឬសាក្សី។</td><td>ពាក្យបណ្ដឹងជំទាស់<br>- នៅពេលទទួលពាក្យបណ្ដឹង កបឃ.ស ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន មានជាអាទិ៍៖<br>○ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬ/និងតំណាង<br>○ កម្មវត្ថុនៃពាក្យបណ្ដឹង និងការគោរពអំឡុងពេលកំណត់១០ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង។<br>- ត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្ដឹង ឬតំណាងផ្ដិតមេដៃលើកំណត់ហេតុនេះ។ ក្នុងករណីអ្នកប្ដឹងមិនព្រមផ្ដិតមេដៃ មេឃុំ ចៅសង្កាត់ ឬជំទប់ ចៅសង្កាត់រង ឬសមាជិកក្រុមប្រឹក្សាដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនោះ<br>- ទ.១២០២ ចំនួន ៤ច្បាប់ ចុះកាលបរិច្ឆេទ ពេលវេលាទទួល កាលបរិច្ឆេទ ពេលវេលាប្រជុំសម្រេច<br>ទ.១២០២ = ៤ ច្បាប់<br>- ១ ច្បាប់ ជូនអ្នកប្ដឹងជំទាស់ ឬតំណាង<br>- ១ ច្បាប់ ជូនអ្នកដែលត្រូវគេប្ដឹងជំទាស់<br>- ១ ច្បាប់ បិទផ្សាយនៅសាលាឃុំសង្កាត់<br>- ១ច្បាប់ ទុកប្រើប្រាស់ក្នុងពេលប្រជុំសម្រេច<br>- ពាក្យបណ្ដឹងដែលគោរពអំឡុងពេលកំណត់ កបឃ.ស ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈ ដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលនៅជាធរមាន និងដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិក កបឃ.ស ក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង<br>-ជូនដំណឹងទៅអ្នកដែលត្រូវគេប្ដឹង</td></tr>
</table>

<table>
<tr><td></td><td>-អ្នកប្ដឹងជំទាស់ត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សី។ អ្នកដែលត្រូវគេប្ដឹងជំទាស់មានសិទ្ធិបដិសេធដោយបង្ហាញឯកសារ។</td></tr>
<tr><td colspan="2">គ. ការប្រជុំសម្រេចជាសាធារណៈ:<br>កបឃ.ស ត្រូវបើកការប្រជុំសម្រេចជាសាធារណៈសម្រេចបដិសេធ ឬយល់ព្រមលើបណ្ដឹង រយៈពេល ៣ថ្ងៃ ដោយធ្វើកំណត់ហេតុប្រជុំសម្រេច។</td></tr>
<tr><td colspan="2">គ.១. ករណីបដិសេធ</td></tr>
<tr><td>ពាក្យបណ្ដឹងតវ៉ា</td><td>ពាក្យបណ្ដឹងជំទាស់</td></tr>
<tr><td>- ស្រង់សេចក្ដីសម្រេចបដិសេធដាក់ក្នុង ទ.១២០៣ ចំនួន ៣ច្បាប់ បញ្ជាក់មូលហេតុ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់<br><br>ទ.១២០៣=៣ច្បាប់<br>- ១ ច្បាប់ ជូនអ្នកប្ដឹងតវ៉ា ឬតំណាង<br>- ១ ច្បាប់ ជូន គ.ជ.ប តាមរយៈ លធ.ខប<br>- ១ ច្បាប់ រក្សាទុកជាឯកសារ<br><br>- ជូន ទ.១២០២ ៣ច្បាប់ដល់អ្នកប្ដឹង (បើសុំ) ជម្រាបគាត់ឱ្យបំពេញចំនួន ៣ច្បាប់ ⇨ រួចយកទៅដាក់នៅ គ.ជ.ប យ៉ាងយូរ៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។</td><td>- ស្រង់សេចក្ដីសម្រេចបដិសេធដាក់ក្នុង ទ.១២០៣ ចំនួន ៤ច្បាប់ បញ្ជាក់មូលហេតុ ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់<br><br>ទ.១២០៣=៤ច្បាប់<br>- ១ ច្បាប់ ជូនអ្នកប្ដឹងជំទាស់ឬតំណាង<br>- ១ច្បាប់ ជូនអ្នកដែលត្រូវគេប្ដឹងជំទាស់<br>- ១ច្បាប់ ជូន គ.ជ.ប តាមរយៈ លធ.ខប<br>- ១ ច្បាប់ រក្សាទុកជាឯកសារ<br><br>- ជូន ទ.១២០២ ៤ច្បាប់ ដល់អ្នកប្ដឹង (បើសុំ) ជម្រាបគាត់ឱ្យបំពេញចំនួន ៤ច្បាប់ ⇨ រួចយកទៅដាក់នៅ គ.ជ.ប យ៉ាងយូរ៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣។</td></tr>
<tr><td colspan="2">គ.២. ករណីយល់ព្រម</td></tr>
<tr><td>ពាក្យបណ្ដឹងតវ៉ា</td><td>ពាក្យបណ្ដឹងជំទាស់</td></tr>
<tr><td>-ស្រង់សេចក្ដីសម្រេចយល់ព្រមដាក់ក្នុង ទ.១២០៣ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់<br><br>ទ.១២០៣=៣ច្បាប់<br>- ១ ច្បាប់ ជូនអ្នកប្ដឹងតវ៉ា ឬតំណាង<br>- ១ ច្បាប់ ជូន គ.ជ.ប តាមរយៈ លធ.ខប<br>- ១ ច្បាប់ រក្សាទុកជាឯកសារ<br><br>-កបឃ.ស អនុវត្តតាមសេចក្ដីសម្រេច រួចកត់ត្រាទុកក្នុង ទ.១០២០ ដើម្បីត្រៀមធ្វើរបាយការណ៍សរុបបញ្ជូនមក ន.គ.ទ.ប នៅពេលបញ្ចប់ការដោះស្រាយពាក្យបណ្ដឹងនៅថ្នាក់ឃុំ សង្កាត់។</td><td>-ស្រង់សេចក្ដីសម្រេចយល់ព្រមដាក់ក្នុង ទ.១២០៣ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់<br><br>ទ.១២០៣=៤ ច្បាប់<br>- ១ ច្បាប់ ជូនអ្នកប្ដឹងជំទាស់ ឬ តំណាង<br>- ១ ច្បាប់ ជូនអ្នកដែលត្រូវគេប្ដឹងជំទាស់<br>- ១ ច្បាប់ ជូន គ.ជ.ប តាមរយៈ លធ.ខប<br>- ១ ច្បាប់ រក្សាទុកជាឯកសារ<br><br>-ជូន ទ.១២០២ ចំនួន ៤ច្បាប់ ដល់អ្នកដែលត្រូវគេប្ដឹង (ប្រសិនបើគាត់ស្នើសុំ) ជម្រាបគាត់ឱ្យបំពេញ រួចយកមកដាក់នៅ គ.ជ.ប រយៈពេលយ៉ាងយូរ ៥ថ្ងៃបន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣<br>- កបឃ.ស ស្រង់កត់ត្រាទុកក្នុង ទ.១០២០ ត្រៀមធ្វើរបាយការណ៍សរុប រួចបញ្ជូនមក ន.គ.ទ.ប នៅពេលបញ្ចប់ការដោះស្រាយពាក្យបណ្ដឹងនៅថ្នាក់ឃុំ សង្កាត់។</td></tr>
</table>

ចំណាំ៖

ក្នុងការប្រជុំសម្រេចលើពាក្យបណ្តឹងតវ៉ា ដែលទាក់ទងនឹងការកែតម្រូវទិន្នន័យ ឬរក្សាទុកក្នុងបញ្ជីបោះឆ្នោត កបឃ.ស ត្រូវយកចិត្តទុកដាក់លើចំណុចដូចខាងក្រោម៖

- ការកែតម្រូវទិន្នន័យ ត្រូវផ្អែកលើឯកសារសំអាងដូចជា អ.ខ ឬ ឯ.អ ដែលបានប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត ដែលការីកុំព្យូទ័របានថតបញ្ជូនតាមប្រព័ន្ធកុំព្យូទ័រមក គ.ជ.ប ។
- ការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត (ករណីឈ្មោះស្ទួន) ត្រូវផ្អែកលើឈ្មោះ និងទិន្នន័យដែលបានចុះឈ្មោះបោះឆ្នោតចុងក្រោយ ឬតាមការស្នើសុំរបស់សាមីខ្លួនដែលផ្អែកលើឯកសារសំអាងច្បាស់លាស់។
- កបឃ.ស អាចទាក់ទងមក ន.គ.ទ.ប តាមរយៈ លធ.ខប ដើម្បីធ្វើការបញ្ជាក់បន្ថែមលើទិន្នន័យអ្នកសុំកែតម្រូវមុននឹងធ្វើការសម្រេចលើពាក្យបណ្តឹងតវ៉ា។

## ២. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

អ្នកប្តឹងតវ៉ា អ្នកប្តឹងជំទាស់ ឬអ្នកត្រូវគេប្តឹងជំទាស់ ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ កបឃ.ស មានសិទ្ធិប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ កបឃ.ស។ អ្នកប្តឹង ឬតំណាងត្រូវបំពេញពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ (ករណីប្តឹងតវ៉ា) ឬ ចំនួន ៤ (បួន) ច្បាប់ (ករណីប្តឹងជំទាស់)។

គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង (ទ.១២០២)។

## ៣. ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

អ្នកប្តឹង ឬតំណាងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ គ.ជ.ប។

ការដាក់ និងការទទួលពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចលើបណ្តឹងតវ៉ា ឬជំទាស់ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ១០ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ការដោះស្រាយពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចយល់ព្រមលើពាក្យបណ្តឹងតវ៉ាឬ/និងពាក្យបណ្តឹងជំទាស់ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តីសម្រេចឱ្យ គ.ជ.ប អនុវត្ត។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

### ៤. ការបំពេញរបាយការណ៍ស្តីពីសេចក្តីសម្រេចកែតម្រូវលើបញ្ជីបោះឆ្នោតដំបូង (ទ.១០២០)

កបឃ.ស ត្រូវបំពេញរបាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូង (ទ.១០២០) ចំនួន ៣ (បី) ច្បាប់ ដោយភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបានសម្រេចឱ្យបញ្ចូលឈ្មោះ ឬ/និងទិន្នន័យបន្ថែម ឬ/និងកែតម្រូវឈ្មោះ ឬ/និងទិន្នន័យពាក់ព័ន្ធក្នុងបញ្ជីបោះឆ្នោត ឬ/និងដែលត្រូវបានសម្រេចលុបចេញពីបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ ព្រមទាំងសម្រង់សេចក្តីសម្រេច (ទ.១២០៣) របស់ កបឃ.ស ពាក់ព័ន្ធតាមករណីនីមួយៗ។

កបឃ.ស ត្រូវបំពេញទម្រង់បែបបទនេះ នៅពេលបញ្ចប់ការដោះស្រាយពាក្យបណ្តឹងនៅថ្នាក់របស់ខ្លួនទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង។ របាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូង (ទ.១០២០) ត្រូវប្រើប្រាស់ដូចខាងក្រោម៖

**ទ.១០២០ ចំនួន ៣ច្បាប់**
- ២ច្បាប់ ផ្ញើជូន គ.ជ.ប តាមរយៈ លធ.ខប
- ១ច្បាប់ រក្សាទុកជាឯកសារនៅឃុំ សង្កាត់។

កបឃ.ស ត្រូវផ្ញើរបាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូង (ទ.១០២០) ជូន គ.ជ.ប (ន.សេវាកម្មច្បាប់ និងវិវាទកម្ម) ចំនួន ២ (ពីរ) ច្បាប់។ កបឃ.ស អាចនឹងត្រូវធ្វើការបំភ្លឺ ឬកែតម្រូវឡើងវិញ ក្នុងករណី គ.ជ.ប ពិនិត្យឃើញថា ទិន្នន័យក្នុងរបាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូង (ទ.១០២០) ឬ/និងសម្រង់សេចក្តីសម្រេច (ទ.១២០៣) មានភាពមិនច្បាស់លាស់។

## ៥. តំនួសបំព្រួញរយៈពេលនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត

### ក.ករណីពាក្យបណ្ដឹងតវ៉ា



## ខ.ករណីពាក្យបណ្ដឹងជំទាស់



### ៦. ការរៀបចំបញ្ជីបោះឆ្នោតផ្លូវការ

នៅពេលដែលពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូងត្រូវបានដោះស្រាយចប់ជាស្ថាពរ គ.ជ.ប ត្រូវបោះពុម្ព និងចាត់បញ្ជូនបញ្ជីបោះឆ្នោតផ្លូវការទៅ លធ.ឧប ចំនួន ១ (មួយ) ច្បាប់ និងសាលាឃុំ សង្កាត់ចំនួន ១ (មួយ) ច្បាប់ ដើម្បីរក្សាទុកជាឯកសារផ្លូវការ។

ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិស្នើសុំពិនិត្យមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោតនេះបាននៅតាមសាលាឃុំ សង្កាត់ ឬនៅ លធ.ឧប ឬតាមអាសយដ្ឋានវេប voterlist.nec.gov.kh ឬតាមកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH។

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតផ្លូវការជាច្បាប់ថតចម្លងបាន ដោយបង់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។

### ៧. ការស្រង់ឈ្មោះអ្នកបោះឆ្នោតដែលបាត់បង់លក្ខខណ្ឌមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងការស្រង់ឈ្មោះប្រជាពលរដ្ឋខ្មែរដែលត្រូវបំពេញលក្ខខណ្ឌដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៅក្រោយពេល គ.ជ.ប ផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត

បន្ទាប់ពីបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ គ.ជ.ប ត្រូវធ្វើការស្រង់ឈ្មោះអ្នកបោះឆ្នោត ដែលបាត់បង់លក្ខខណ្ឌមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងប្រជាពលរដ្ឋខ្មែរដែលត្រូវបំពេញលក្ខខណ្ឌ ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត សម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតប្រចាំឆ្នាំ តាមឃុំ សង្កាត់នីមួយៗ។ ស្មៀនឃុំ សង្កាត់ ត្រូវបំពេញតួនាទីខាងលើនេះ ដោយធ្វើការសហការជាមួយ លធ.ឧប។ ស្មៀនឃុំ សង្កាត់ និង កបឃ.ស ត្រូវស្រង់ឈ្មោះ៖

- អ្នកបោះឆ្នោតដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ហើយមានឯកសារសំអាងត្រឹមត្រូវ និងច្បាស់លាស់ ដាក់ក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត (ទ.១០២៥) ហើយត្រូវថតចម្លងបញ្ជីនេះជូន គ.ជ.ប តាមរយៈ លធ.ឧប រៀងរាល់២ខែម្តង
- ប្រជាពលរដ្ឋខ្មែរដែលមិនទាន់បានចុះឈ្មោះពីមុនមក ឬ/និងដែលទើបដល់អាយុត្រូវបោះឆ្នោត ឬ/និងបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មីដាក់ក្នុងបញ្ជីឈ្មោះអ្នកមានសិទ្ធិបោះឆ្នោត (ទ.១០២៧) ដែលនឹងត្រូវអញ្ជើញមកចុះឈ្មោះបោះឆ្នោត ហើយត្រូវថតចម្លងបញ្ជីនេះជូន គ.ជ.ប តាមរយៈ លធ.ឧប រៀងរាល់២ខែម្តង។

ក្នុងអំឡុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ គ.ជ.ប តាមរយៈ លធ.ខប ត្រូវធ្វើការសហការជាមួយ ក.ច.ប នៃឃុំ សង្កាត់នីមួយៗ ដើម្បីលុបឈ្មោះអ្នកបោះឆ្នោតដែលបានទទួលមរណភាព ឬត្រូវបានដកហូតជាបណ្ដោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ឬ/និងជូនដំណឹងដល់ប្រជាពលរដ្ឋខ្មែរដែលមិនទាន់បានចុះឈ្មោះពីមុនមក ឬ/និងដែលទើបដល់អាយុត្រូវបោះឆ្នោត ឬ/និងបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ឱ្យមកចុះឈ្មោះបោះឆ្នោត ឱ្យមកបំពេញលក្ខខណ្ឌ និងនីតិវិធីទាំងឡាយសម្រាប់ការចុះឈ្មោះបោះឆ្នោត៕

## តារាងសង្ខេបទម្រង់បែបបទដែលត្រូវប្រើប្រាស់តាមលំដាប់ថ្នាក់

## សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

| ក្រុមចុះឈ្មោះបោះឆ្នោត | | ក្រុមប្រឹក្សាឃុំ សង្កាត់ | | លេខាធិការដ្ឋានរាជធានី ខេត្ត រៀបចំការបោះឆ្នោត | |
|---|---|---|---|---|---|
| លេខទម្រង់ | ខ្លឹមសារ | លេខទម្រង់ | ខ្លឹមសារ | លេខទម្រង់ | ខ្លឹមសារ |
| ១០០៩ | សេចក្តីសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត | ១០០១ | កិច្ចសន្យាបម្រើការងារជាមន្ត្រីចុះឈ្មោះបោះឆ្នោត | ១០១៤ | លិខិតបញ្ជាក់ការវេចខ្ចប់ស្បោង «ខ» និងការបញ្ជូនស្បោង «គ» ដោយ លធ.ខប |
| ១០១១ | របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមការិយាល័យបោះឆ្នោត | ១០០៦ | តារាងប្រាក់កម្រៃមន្ត្រីចុះឈ្មោះបោះឆ្នោត | ១០១៥ | លិខិតបញ្ជាក់សម្ភារឯកសារចុះឈ្មោះបោះឆ្នោតដែលត្រូវបានផ្គត់ផ្គង់បន្ថែម |
| ១០១២ | របាយការណ៍សរុបស្តីពីលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ | ១០០៧ | ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ | ១១០៧ | លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារពេលចុះឈ្មោះបោះឆ្នោត |
| ១០១៣ | លិខិតបញ្ជាក់ការវេចខ្ចប់សម្ភារឯកសារចុះឈ្មោះបោះឆ្នោត និងការបញ្ជូនស្បោង«ខ»ដោយក្រុមចុះឈ្មោះបោះឆ្នោត | ១០២០ | របាយការណ៍ស្តីពីសេចក្តីសម្រេចរបស់ កបឃ.ស កែតម្រូវលើបញ្ជីបោះឆ្នោតដំបូងនៃឃុំ សង្កាត់ | | |
| ១០២១ | របាយការណ៍ស្តីពីគុណភាពនៃការទទួល និងការប្រើប្រាស់ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត | ១០២៤ | កំណត់ហេតុវាយតម្លៃសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត | | |
| ១០២២ | ទម្រង់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (មានអត្តលេខ និងគ្មានអត្តលេខ) | ១១០៧ | លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារពេលចុះឈ្មោះបោះឆ្នោត | | |
| ១០២៨ | បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និង កែតម្រូវទិន្នន័យ | ១២០២ | ពាក្យបណ្តឹង | | |
| ១០២៩ | របាយការណ៍ស្តីពីលទ្ធផលនៃការពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំថ្ងៃក្នុងឃុំ សង្កាត់ | ១២០៣ | សម្រង់សេចក្តីសម្រេច | | |
| ១១០៧ | លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារពេលចុះឈ្មោះបោះឆ្នោត | | លិខិតស្នើសុំឯកសារបញ្ជាក់អត្តសញ្ញាណនិងឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត | | |
| ១២០២ | ពាក្យបណ្តឹង | | លិខិតបញ្ជាក់ទីលំនៅ | | |

# ភារកិច្ចសង្ខេបរបស់ក្រុមចុះឈ្មោះបោះឆ្នោត និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រចាំការ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

## កម្លាំងរក្សាសណ្ដាប់ធ្នាប់

- សម្រួលសណ្ដាប់ធ្នាប់សម្រាប់ប្រជាពលរដ្ឋ ដែលចូលមកកាន់ការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីសុំកែតម្រូវឈ្មោះ និងទិន្នន័យ ឬ/និងសុំចុះឈ្មោះបោះឆ្នោត។
- សម្រួលអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្ដង ៣នាក់។
- ផ្ដល់អាទិភាពចំពោះព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ឬស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាពចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។
- អនុញ្ញាតឱ្យជំនួយជានីតិជនម្នាក់ជូនដំណើរជនមានពិការភាពដែលមិនអាចចុះឈ្មោះបោះឆ្នោតដោយខ្លួនឯងបាន ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។
- រាយការណ៍ជាបន្ទាន់ជូនប្រធាន ក.ច.ប ដើម្បីរាយការណ៍បន្តជូនសមាជិក កបឃ.ស ប្រចាំការ ដើម្បីរាយការណ៍ជូន កបឃ.ស ក្នុងករណីមានការអុកឡុករំខានពីជនណាម្នាក់ ឬច្រើននាក់ ដើម្បីមានវិធានការស្នើសុំអន្តរាគមន៍ពីភ្នាក់ងារសន្តិសុខ ឬ/និងអាជ្ញាធរមានសមត្ថកិច្ច។

## សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ប្រចាំការ

- ដឹកនាំ ក.ច.ប ឱ្យអនុវត្តឱ្យបានត្រឹមត្រូវតាម ច.ប.ត.រ ច.ប.ឃ.ស និង ប.ន.ព.ច។
- ប្រចាំការពិនិត្យមើលដំណើរការចុះឈ្មោះបោះឆ្នោត និងរាយការណ៍ជាប្រចាំជូន កបឃ.ស អំពីភាពជឿនលឿននៃការចុះឈ្មោះបោះឆ្នោត។
- រក្សាសណ្ដាប់ធ្នាប់តាមលទ្ធភាព និងការចាំបាច់សម្រាប់សម្រួលដល់ការចុះឈ្មោះបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់។
- ធានាថារាល់កិច្ចប្រតិបត្តិការទាក់ទងដល់ការចុះឈ្មោះបោះឆ្នោត បានប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការភ័យខ្លាច គ្មានការបង្ខិតបង្ខំ និងគ្មានការគំរាមកំហែង។
- រាយការណ៍ជូន កបឃ.ស ដើម្បីចាត់ចែងដោះស្រាយឱ្យមានអន្តរាគមន៍ពីកម្លាំងនគរបាល ឬកម្លាំងមានសមត្ថកិច្ច តាមសំណើរបស់ ក.ច.ប ក្នុងករណីដែល មានជនណាបង្កការអុកឡុក រំខាន គំរាមកំហែង ឬប្រព្រឹត្តអំពើល្មើសច្បាប់ សំដៅបង្អាក់ដំណាក់កាលណាមួយនៃការចុះឈ្មោះបោះឆ្នោត។

## ប្រធាន ក.ច.ប

- ធ្វើសម្ភាសន៍អ្នកសុំចុះឈ្មោះបោះឆ្នោតនិងសាកសួរព័ត៌មានគាត់ថា៖
  - តើមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតឬទេ ?
  - តើគាត់បានចុះឈ្មោះបោះឆ្នោតហើយ ឬនៅ ?
- ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ឬ ឯ.អ និងមិនទាន់បានចុះឈ្មោះបោះឆ្នោត ប្រធាន ក.ច.ប ត្រូវពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះដូចខាងក្រោម៖
  - ផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ
  - មានអាយុចាប់ពី ១៨ឆ្នាំ ឡើង គិតដល់ថ្ងៃបោះឆ្នោតទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
  - មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត។
- ជម្រាបអ្នកសុំចុះឈ្មោះឱ្យទៅជួបអនុប្រធាន ក.ច.ប ដើម្បីបន្តនីតិវិធីចុះឈ្មោះបោះឆ្នោត តាមជំហានបន្តបន្ទាប់ (ក្នុងករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានបំពេញគ្រប់លក្ខខណ្ឌកំណត់)។
- មានសិទ្ធិសម្រេចក្នុងការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត (ចុះឈ្មោះជូនអ្នកផ្លាស់ចូលក្នុងឃុំ សង្កាត់ថ្មី ប្ដូរការិយាល័យក្នុងឃុំ សង្កាត់ កែតម្រូវទិន្នន័យជីវប្រវត្តិ ធ្វើបច្ចុប្បន្នភាពជីវមាត្រ និងស្នើសុំលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត)
- មានសិទ្ធិសម្រេចបដិសេធការសុំចុះឈ្មោះបោះឆ្នោត ដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ (ចេញ ទ.១០០៩) ដោយបញ្ជាក់ពីមូលហេតុនិងលក្ខខណ្ឌដែលអ្នកសុំចុះឈ្មោះបោះឆ្នោតមិនបានបំពេញ។
- ធ្វើការកត់ត្រាចូលក្នុងរបាយការណ៍ជូន គ.ជ.ប ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតដែលមិនអាចផ្ដល់ស្នាមម្រាមដៃបាន។

## អនុប្រធាន គ.ច.ប ឬសមាជិកដែលជួយការងារអនុប្រធាន គ.ច.ប

- សួរទីលំនៅ នៅភូមិណា ដើម្បីកំណត់បញ្ចូលឈ្មោះក្នុងការិយាល័យបោះឆ្នោតក្នុងភូមិនោះ។
- បំពេញ ទ.១០២២ មានអត្តលេខ ឬ ទ.១០២២ គ្មានអត្តលេខ សម្រាប់អ្នកផ្លាស់ប្តូរទីលំនៅចូលថ្មី ដោយផ្អែកតាមទិន្នន័យក្នុង អ.ខ ឬ ឯ.អ។
- បំពេញ ទ.១០២៨ ដកហូតបង្កាន់ដៃទ.១០២២ចាស់កិបភ្ជាប់ជាមួយគល់ ទ.១០២៨សម្រាប់អ្នកប្តូរការិយាល័យក្នុងឃុំ សង្កាត់ និងអ្នកសុំកែតម្រូវឈ្មោះនិងទិន្នន័យនិងអ្នកសុំធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ។
- ប្រគល់ អ.ខឬឯ.អឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ និងបង្កាន់ដៃ ទ.១០២២ ឬទ.១០២៨ ទៅការីកុំព្យូទ័រ និងជម្រាបអ្នកសុំចុះឈ្មោះបោះឆ្នោត ឬអ្នកសុំកែតម្រូវទិន្នន័យនោះឱ្យទៅជួបការីកុំព្យូទ័រ។

## ការីកុំព្យូទ័រ

- កត់ត្រាទិន្នន័យអ្នកសុំចុះឈ្មោះទៅក្នុងកម្មវិធីកុំព្យូទ័រដោយផ្អែកតាម អ.ខ ឬ ឯ.អ និងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត ដូចខាងក្រោម៖
  - ជ្រើសយកឈ្មោះ ទីតាំង និងលេខកូដការិយាល័យបោះឆ្នោត តាម ទ.១០២២ ឬ ទ.១០២៨
  - ស្វែងរកឈ្មោះ និងទិន្នន័យរបស់អ្នកសុំចុះឈ្មោះតាម អ.ខ ឬឯ.អ។ បន្ទាប់ពីទិន្នន័យបានបង្ហាញ ត្រូវធ្វើការផ្ទៀងផ្ទាត់រូបថតជាមួយនឹងទិន្នន័យ តាមកម្មវិធីកុំព្យូទ័រដែលបានកំណត់
  - ប្រសិនបើឈ្មោះនិងទិន្នន័យព្រមទាំងរូបថតរបស់សាមីខ្លួនត្រឹមត្រូវហើយការីកុំព្យូទ័រត្រូវធ្វើការទាញយកទិន្នន័យមួយចំនួនដែលរួមមានអត្តលេខ លេខអ.ខ ឬឯ.អ នាមត្រកូលនិងនាមខ្លួនបន្ទាប់មកបញ្ចូលអាសយដ្ឋានអ្នកសុំចុះឈ្មោះបោះឆ្នោត ដោយផ្អែកតាម អ.ខ ឬ ឯ.អ ឬ/និងឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់(ប្រសិនបើមាន)
  - ជូតសម្អាតមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតជាមុន បន្ទាប់មកធ្វើតេស្តស្នាមមេដៃទាំងសងខាងសម្រាប់ដំណើរការកម្មវិធី។ ចំពោះអ្នកពិការដៃម្ខាង ឬទាំងសងខាង ឬគ្មានស្នាមម្រាមដៃ ស្នើសុំប្រធាន គ.ច.ប ដើម្បីដំណើរការកម្មវិធី
  - ថត អ.ខ ឬ ឯ.អ
  - ជ្រើសរើសប្រវត្តិចុះឈ្មោះបោះឆ្នោត
  - ជ្រើសរើសយកប្រភេទឯកសារសម្រាប់ប្រើចុះឈ្មោះបោះឆ្នោត (អ.ខ ឬ ឯ.អ) និងបញ្ចូលលេខ អ.ខ ឬ ឯ.អ
  - បញ្ចូលអត្តលេខ អ្នកសុំចុះឈ្មោះដែលមាននៅក្នុងបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២)
  - បញ្ចូលនាមត្រកូល នាមខ្លួន ភេទ ថ្ងៃ ខែ ឆ្នាំកំណើត
  - បញ្ចូលលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់របស់សាមីខ្លួន។
- ផ្ទេរឈ្មោះ និងទិន្នន័យអ្នកសុំប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទៅការិយាល័យបោះឆ្នោតថ្មីក្នុងភូមិដែលគាត់រស់នៅ តាមការកំណត់ក្នុងបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨)។
- ជួយកាន់មេដៃអ្នកសុំចុះឈ្មោះបោះឆ្នោតដាក់លើស្កេនស្កាននស្នាមម្រាមដៃដើម្បីយកស្នាមមេដៃសាមីខ្លួនទាំងសងខាងបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រដោយត្រូវស្កេនមេដៃម្ខាងៗចំនួន៤ដង។ ក្នុងករណីអ្នកសុំចុះឈ្មោះពិការមេដៃណាមួយ ឬទាំងសងខាង។ ត្រូវយកស្នាមម្រាមដៃបន្តបន្ទាប់ជំនួស ហើយក្នុងករណីអ្នកសុំចុះឈ្មោះពិការដៃម្ខាងត្រូវយកស្នាមមេដៃម្ខាងដែលមាន។ ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ត្រូវធ្វើការកត់ត្រាចូលក្នុងរបាយការណ៍ជូន គ.ជ.ប។
- ថតរូបអ្នកសុំចុះឈ្មោះបោះឆ្នោតចំពីមុខ។
- ថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ (ប្រសិនបើមាន) ក្នុងការថតឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ ការីកុំព្យូទ័រត្រូវថតគ្រប់ទំព័រនៃសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ (ថតសន្លឹកដែលមានទិន្នន័យពាក់ព័ន្ធ) ឬលិខិតបញ្ជាក់ទីលំនៅ ។
- ជម្រាបអ្នកសុំចុះឈ្មោះឱ្យគាត់ផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួនដែលបានបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២។ ករណីអ្នកសុំចុះឈ្មោះមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យរបស់គាត់។
- រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ។ ចំពោះអ្នកសុំចុះឈ្មោះដែលមិនអាចផ្តល់ស្នាមម្រាមដៃបាន ស្នើសុំប្រធាន គ.ច.ប ផ្តល់សិទ្ធិសម្រាប់រក្សាទុកទិន្នន័យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ។
- ប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត និង អ.ខ ឬឯ.អ ឬឯកសារបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត។ បញ្ជូនទិន្នន័យអ្នកបោះឆ្នោតទៅ ន.គ.ទ.ប ម្តង ១០នាក់ ឬតាមលទ្ធភាពដែលអាចធ្វើបាន។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ថ្ងៃព្រហស្បតិ៍ ៤កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមករា ឆ្នាំ២០២៦

## ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

| ល.រ | ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ | ថ្ងៃទី៧ ខែកញ្ញា - ៦ ខែតុលា ឆ្នាំ២០២៦ |
| ២ | ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអ្នកសារព័ត៌មានជាតិ | ថ្ងៃទី៧ខែកញ្ញា ឆ្នាំ២០២៦-២ ខែកុម្ភៈ ឆ្នាំ២០២៧ |
| ៣ | ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ និងអ្នកសារព័ត៌មានអន្តរជាតិ | ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៦-៩ ខែកុម្ភៈ ឆ្នាំ២០២៧ |
| ៤ | ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ | ថ្ងៃទី៣០ខែកញ្ញា ឆ្នាំ២០២៦-២ខែកុម្ភៈ ឆ្នាំ២០២៧ |
| ៥ | ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត | ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦ |
| ៦ | ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ និងបង្ហោះលើអាសយដ្ឋានវេបរបស់ គ.ជ.ប voterlist.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH | ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦ |
| ៧ | ការចាប់ផ្តើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ | ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៦ |
| ៨ | ការបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ | ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦ |
| ៩ | ការប្តឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣ថ្ងៃ | ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១០ | ការដោះស្រាយពាក្យបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣ថ្ងៃ | ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១១ | ការប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១២ | ការដោះស្រាយពាក្យបណ្តឹងតវ៉ាដោយ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១៣ | ការប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១៤ | ការដោះស្រាយពាក្យបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី២ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ១៥ | ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ទូទាំងប្រទេស | ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៧ |
| ១៦ | ការប្តឹងតវ៉ា ឬការប្តឹងជំទាស់លើបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ១៧ | ការដោះស្រាយពាក្យបណ្តឹងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣ថ្ងៃ | ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ១៨ | ការប្តឹងតវ៉ា ឬការប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ១៩ | ការដោះស្រាយពាក្យបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ២០ | ការប្តឹងតវ៉ា ឬការប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ២១ | ការដោះស្រាយពាក្យបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ២២ | ការផ្តល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការដោយ គ.ជ.ប | ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៧ |

មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ, កម្ពុជា
Samdach Sothearos Blvd, Sangkat Tonle Bassac, Khan Chamkar Morn, Phnom Penh, Cambodia
ទូរសព្ទ : (+855) 23 23 52 53
អ៊ីមែល : info@nec.gov.kh

# បោះពុម្ពផ្សាយដោយ គ.ជ.ប
# ឆ្នាំ២០២៦

អាសយដ្ឋាន៖ អគារទីស្ដីការ គ.ជ.ប មហាវិថីសម្ដេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

លេខទូរសព្ទ ០២៣ ២១៤ ៣៧៤ , ០២៣ ២១៤ ២៣១, ០១២ ៨៥៥ ០១៨